ព្រះ
ត្រៃបិដកចារលើ
ទឹក
សេចក្តីប្រែជាភាសាខ្មែរ
សុត្តន្តបិដក
ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ
តតិយភាគ
៧១



ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ
៣-ស ២៥០៥

ឯកសារគម្ពីរព្រះត្រៃបិដកស្កានេះ
ត្រូវបានថតចេញពី ច្បាប់គម្ពីរព្រះត្រៃបិដកជប៉ុន ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះ ចាប់ពីភាគ៥១ ដល់ ភាគ១១០
ត្រូវបានវៀបចំធ្វើទៅឡើងដោយ គេហទំព័រ៥000ឆ្នាំ បូជា
ចំពោះព្រះពុទ្ធសាសនា សម្រាប់ជាធម្មទាន ។

ផ្តល់សៀវភៅគម្ពីរព្រះត្រៃបិដកសម្រាប់ការងារ
ដោយ ឧបាសិកា កាំង ហ្គិចណៃ ។

គ្រប់គ្រងគម្រោង (ទូទៅ និងផ្នែកបច្ចេកទេស)
ដោយ ឧបាសក ស្រុង-ចាន់ណា ។

ត្រួតពិនិត្យឡើងវិញ
ដោយ ចន-ស្រីស្រស់ ។


ថតស្កានដោយ
ភ្នួនប្រុស ម៉ាន់ សាវ៉ែត

www.5000-years.org

ក្រោមការឧបត្ថម្ភយ៉ាងក្រៃលែងអំពីៈ

- ឧបាសិកា កាំង ហ៊ួចណៃ (ភ្នំពេញ)
- ឧបាសក ដុត លីស្រុង និង ឧបាសិកា លី សុខា ព្រមទាំងបុត្រ (ភ្នំពេញ)
- ឧបាសក សន ចន និង ឧបាសិកា អ៊ូច សាទៀង ព្រមទាំងបុត្រ (បាត់ដំបង)
- ឧបាសក ជា ស៊ុវត្ថានា និងឧបាសិកា ឃុន សូនីម៉ា ព្រមទាំងបុត្រី ជា សុមេធាធីតា (ស.ទ.អ)
- លោក ជីម-ជា និងលោកស្រី រតនំ ស្រីមុំ (ភ្នំពេញ)
- ឧបាសក ផែង យឿន (កូរ៉ែ)
- លោក ស៊ុក ចាន់សេរី (បន្ទាយមានជ័យ)
- ឧបាសិកា យ៉ា វ៉ានី (បន្ទាយមានជ័យ)
- ប្អូនស្រី យ៉ា សុភៈ (បន្ទាយមានជ័យ)
- ឧបាសិកា កោ សេង (ភ្នំពេញ)
- លោកស្រី ប៉ាន សុគន្ធានីន និងស្វាមី ព្រមទាំងបុត្រ (ភ្នំពេញ)
- ឧបាសក ស្រុង ចាន់ណា និង ឧបាសិកា ចន ស្រីស្រស់
  ព្រមទាំងបុត្រ ចាន់ណា សុធានធីរាជ, ចាន់ណា សុធានធិរោធ (ភ្នំពេញ)
- លោកស្រី ស្រុង ចាន់រស្មី និង ស្វាមី ព្រមទាំងបុត្រ (ភ្នំពេញ)
- កញ្ញា ស្រុង ចាន់រតនា (ភ្នំពេញ)
- លោក ស្រុង ឃូហេង (ភ្នំពេញ)
- លោក នង សុផល (កូរ៉ែ)
- ប្អូនស្រី សុខ អេង (កំពង់ចាម)
- កញ្ញា ចន កក្កដា (បាត់ដំបង)
- លោកស្រី ចន សត្យា និងលោក ឡូត សេរីសំភ ព្រមទាំងបុត្រ (ភ្នំពេញ)
- លោក ចន រចនា (បាត់ដំបង)
- កញ្ញា ស៊ែ សុផានី (បាត់ដំបង)
- កញ្ញា យឿម សុផានី (បាត់ដំបង)
- លោក ម៉ៅ គន្ធា និងលោកស្រី ធៀង សេដ្ឋា (បាត់ដំបង)
- លោក សៅ សារ៉ុម (បាត់ដំបង)
- ព្រះតេជព្រះគុណ ជុំ សារៈ (ព្រះចៅអធិការវត្ត សម សាន្ត ខេត្តបាត់ដំបង)
- ឧបាសិកា វ៉ាន់ លុយ និងស្វាមី ព្រមទាំងបុត្រ (ភ្នំពេញ)
- លោកស្រី ហួ ច័ន្ទសុវណ្ណ និងស្វាមី ព្រមទាំងបុត្រ (ស.ទ.អ)

ព្រះ
ត្រៃបិដកបាលី
និង
សេចក្តីប្រៀបធៀបភាសាខ្មែរ
សុត្តន្តបិដក
ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ
ឥតិយកាត
៧១



ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

ព.ស. ២៥០៥

ឧទ្ទិសកថា

យើងខ្ញុំ សូមផ្តល់ស្មារតីស្វ្រព្រះធម៌ឧទ្ទិសជូនជនជាតិខ្មែរ ។
ឥឡូវ យើងខ្ញុំអាចជូនគម្ពីរព្រះត្រៃបិដកនេះ ទៅអ្នកកាន់ព្រះពុទ្ធសាសនាជនជាតិខ្មែរបានហើយ ។
ព្រះធម៌នៃព្រះពុទ្ធជាម្ចាស់នេះ ត្រូវបានស្វ្រចេញពីជម្រៅដួងចិត្តនៃអ្នកកាន់ព្រះពុទ្ធសាសនា
ជនជាតិជប៉ុន ។

このカンボジア版南伝大蔵経を
カンボジアの佛教徒へ
贈ることができることに感謝します。
これが日本の佛教徒の心です。

It is with a deep sense of gratitude that I present the translation of the complete TRIPITAKA to Cambodian Buddhists on behalf of the Japanese Buddhist community.

អារម្ភកថា

ជូនចំពោះជនជាតិខ្មែរ ជាទីរាប់អាន !

ជូនចំពោះជនជាតិខ្មែរដែលកាន់ព្រះពុទ្ធសាសនា ជាទីគោរព !

គម្ពីរព្រះត្រៃបិដកខ្មែរនេះ ត្រូវបាន" ក្រុមជំនុំព្រះត្រៃបិដក" នៃពុទ្ធសាសនបណ្ឌិត្យ នៅភ្នំពេញ បកប្រែពីភាសាបាលីមកជាភាសាខ្មែរ តាំងពីឆ្នាំ ១៩៣០ ទៅឆ្នាំ ១៩៦៨ គឺត្រូវចំណាយពេល ៣៩ ឆ្នាំ ទើបបានសម្រេចហើយសព្វគ្រប់ ។ នេះពិតជាកំណប់ព្រះធម៌របស់ព្រះពុទ្ធសាសនាខ្មែរ ហើយក៏ជាកំណប់វប្បធម៌ខាងផ្នែកបោះពុម្ពរបស់ជនជាតិខ្មែរផងដែរ ។ យើងខ្ញុំ ពុទ្ធសាសនិកជាតិជប៉ុន មានសន្តានចិត្តរីករាយនឹងបោះពុម្ពជាថ្មីម្តើងវិញ ដោយសង្ឃឹមថា ព្រះពុទ្ធសាសនាខ្មែរក៏នឹងរុងរឿងម្តើងវិញដែរ ។

នេះគឺជាអំណោយពីជម្រៅដួងចិត្ត ជូនទៅដល់ជនជាតិខ្មែរទាំងអស់ ព្រមទាំងមនុស្សជាតិទូទៅ នៅក្នុងពិភពលោកនេះ ដែលមានចិត្តស្រឡាញ់សន្តិភាព ។

ខ្មែរបានរងសោកនាដកម្មដែលមិនធ្លាប់មានពីមុនមក ។ ម្យ៉ាងទៀត ព្រះពុទ្ធសាសនាខ្មែរ ក៏ត្រូវរន្ធត់រាយយ៉ាងខ្លាំង ក៏ប៉ុន្តែឥឡូវនេះ យើងទាំងអស់គ្នា បានឈានជើងកន្លងផុតពីសេចក្តីទុក្ខសោកដ៏ធ្ងន់ធ្ងរនេះ ចាកផុតពីអំពើហោរយោ បញ្ចប់គំនុំគុំគួន ដើរតាមពុទ្ធដីកាព្រះបរមគ្រូ ខិតខំព្យាយាមធ្វើឱ្យមានសន្តិភាពក្នុងពិភពលោក ។

ការណ៍ដែលយើងខ្ញុំជូនគម្ពីរព្រះត្រៃបិដកពេលនេះ គឺជានិមិត្តរូបនៃការប្តេជ្ញាចិត្តរបស់អ្នកកាន់ព្រះពុទ្ធសាសនាជនជាតិជប៉ុនថា យើងខ្ញុំធ្វើសហប្រតិបត្តិការដើម្បីសន្តិភាពក្នុងពិភពលោក ដើម្បីទុកជាភស្តុតាងនៃចំណងមេត្រីភាព និងមិត្តភាពរវាងប្រជាជាតិជប៉ុន និងប្រជាជាតិខ្មែរ ។

ថ្ងៃទុត្តិយកក្ក កក្កដា ឆ្នាំ ១៩៩៤

សមាគមជំនួយដល់ការបោះពុម្ពព្រះត្រៃបិដកម្តើងវិញ

អ្នកតំណាងចាត់ការ The Rev. Seikyo Muchaku

ប្រធានការិយាល័យ The Rev. Eiitsu Shinohara

អ្នកចាត់ការ

The Rev. Zendo Matsunaga The Rev. Jitsujo Arima The Rev. Yoshimichi I
The Rev. Keiichi Watai The Rev. Gijun Sugitani The Rev. Shincho Shigeta
The Rev. Risho Maeda The Rev. Kyoshi Nakajima Mr. Rokusuke Ei

『トリピタカ』復刻進呈にあたって

親愛なるカンボジアの皆さん！
敬愛するカンボジアの仏教徒の皆さん！

カンボジア版『トリピタカ』は、プノンペンの仏教研究所が、仏教界の英知を集め、1930年から1968年まで、39年の歳月をかけて翻訳し、分類し、集大成して完成されました。まさにカンボジア仏教の法宝であると共に、カンボジア出版文化の至宝です。日本仏教徒の有志は、カンボジア仏教の復興再生を願いつつ、これを復刻刊行し、贈らせていただきます。

これはカンボジア仏教徒のみならず、カンボジア全人民、否、平和を愛する地球上のすべての人々への、心からの贈り物です。

カンボジアは、古今未曾有の悲劇を体験しました。カンボジア仏教もこの受難の時代に壊滅的な打撃を受けました。しかし、今はその悲しみを乗りこえ、瞋りを離れ、怨みを怨し、ブッダの教えに従い、世界平和の実現に努力するときです。

この本の贈呈は、日本の仏教徒も共々に、世界平和のために努力することを誓うしるしであり、相互の連帯と友情の証なのです。

合掌

1994年７月吉日

カンボジア版トリピタカ（南伝大蔵経）復刻救援委員会

世話人代表	無着　成恭	世話人	松永　然道	有馬　実成
事務局長	篠原　鋭一		伊藤　佳通	渡井　奎一
			杉谷　義純	茂田　真澄
			前田　利勝	中島　教之
			永　六輔	

Acknowledgment

Dear Cambodian friends and respected members of the Cambodian Buddhist community,

It is a matter of great joy that the translation into Cambodian of the Pali Tripitaka has been completed and published. The Tripitaka Commisson of the Buddhist Institute, Phnom Penh, launched the translation project in 1930 and completed the translation, after 39 years of effort, in 1968.

The Cambodian translation of this great work will not only become a cherished treasure of the Cambodian Buddhist community but will also be an important milestone in the history of publication in Cambodia.

The revival and prosperity of Buddhism in Cambodia are the ardent wish of the Japanese Buddhist community, it is in this spirit that we have completed this important project and now present the entire work to the Cambodian Buddhist community, it is a gift not only to the Buddhist community in Cambodia but also to all Cambodian people and all peace-loving people in the world.

Cambodia experienced great tragedies in modern times, and the Cambodian Buddhist community also underwent severe trials and suffered crushing blows during this period. But now a time has come to surmount grief and anger, to forgive, and to start working again for world peace.

This great work is a symbol of the Japanese Buddhist community's resolve to work with our Cambodian brothers and sisters toward world peace and is a testimony to the friendship between our people.

With hands joined in reverence.
July 1994

TRIPITAKA PUBLISHING SUPPORT COMMITTEE
Project Manager : The Rev. Seikyo Muchaku
Secretary General : The Rev. Eiitsu Shinohara
Management Team :
The Rev. Zendo Matsunaga The Rev. Jitsujo Arima The Rev. Yoshimichi Ito
The Rev. Keiichi Watai The Rev. Gijun Sugitani The Rev. Shincho Shigeta
The Rev. Risho Maeda The Rev. Kyoshi Nakajima Mr. Rokusuke Ei

សុត្តន្តបិដក

ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ

តតិយភាគ

៧១

ព.ស. ២៤៨៦

សុត្តន្តបិដកេ

ខុទ្ទកនិកាយស្ស បដិសម្ភិទាមគ្គេ

តតិយោ ភាគោ

មហាវគ្គេ មណ្ឌបេយ្យកថា

[១] មណ្ឌបេយ្យមិទំ ភិក្ខវេ ព្រហ្មចរិយំ សត្ថរិ សម្មុខីភូតេ តិវិធោ មណ្ឌោ សត្ថរិ សម្មុខីភូតេ ទេ-សនាមណ្ឌោ បដិក្ខេបមណ្ឌោ ព្រហ្មចរិយមណ្ឌោ ។

កតមោ ទេសនាមណ្ឌោ ។ ចត្តារិ អរិយសច្চានិ អាចិក្ខណា ទេសនា បញ្ញបនា បដ្ឋបនា វិវរណា វិភជនា ឧត្តានីកម្មំ ចត្តារិ សតិបដ្ឋានានិ ។ បេ ។ ចត្តារិ សម្មប្បធានានិ ចត្តារិ ឥទ្ធិបាទានិ បញ្ច ឥន្ទ្រិយានិ បញ្ច ពលានិ សត្ត ពោជ្ឈង្គានិ អរិយស្ស អដ្ឋង្គិកស្ស មគ្គស្ស អាចិក្ខណា ទេសនា បញ្ញបនា បដ្ឋបនា វិវរណា វិភជនា ឧត្តានីកម្មំ អយំ ទេសនាមណ្ឌោ ។

កតមោ បដិក្ខេបមណ្ឌោ ។ ភិក្ខុ ភិក្ខុនិយោ ឧបាសកា ឧបាសិកាយោ ទេវា មនុស្សា យេ វា បនញ្ញេបិ កេចិ វិញ្ញាតារោ អយំ បដិក្ខេបមណ្ឌោ ។

សុត្តន្តបិដក

ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ

តតិយភាគ

មហាវគ្គ មណ្ឌបេយ្យកថា

[១] ម្នាលភិក្ខុទាំងឡាយ កាលព្រះសាស្តាគង់នៅកន្លងទីបំពោះមុខ ព្រហ្មចរិយៈនេះ ឋិតក្នុងភាពជាក្រេចផឹក កាលព្រះសាស្តាគង់នៅកន្លងទីបំពោះមុខ សភាពថ្លាមាន ៣ យ៉ាង គឺទេសនាថ្លា ១ អ្នកទទួលថ្លា ១ ព្រហ្មចរិយៈថ្លា ១ ។

ទេសនាថ្លា តើដូចម្តេច ។ ការប្រាប់ ការសំដែង ការបញ្ញត្តិ ការតាំងទុក ការបើក ការវែកញែក ការធ្វើឲ្យពាក់ នូវអរិយសច្ច ៤ ការប្រាប់ ការសំដែង ការបញ្ញត្តិ ការតាំងទុក ការបើក ការវែកញែក ការធ្វើឲ្យពាក់ នូវសតិប្បដ្ឋាន ៤ ។ បេ ។ នូវសម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ អរិយមគ្គមានអង្គ ៨ នេះទេសនាថ្លា ។

អ្នកទទួលថ្លា តើដូចម្តេច ។ ពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ទេវតានិងមនុស្ស ឬពួកជនដទៃណាមួយជាអ្នកដឹង នេះអ្នកទទួលថ្លា ។

កតមោ ព្រហ្មចរិយមណ្ឌោ ។ អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ ។ សេយ្យថីទំ ។ សម្មាទិដ្ឋិ សម្មាសង្កប្បោ សម្មាវាចា សម្មាកម្មន្តោ សម្មាអាជី-វោ សម្មាវាយាមោ សម្មាសតិ សម្មាសមាធិ អយំ ព្រហ្មចរិយមណ្ឌោ ។

(២) អធិមោក្ខមណ្ឌោ សទ្ធិន្ទ្រិយំ អស្សទ្ធិយំ កសរោ អស្សទ្ធិយំ កសដំ ឆេត្វា សទ្ធិន្ទ្រិយស្ស អធិមោក្ខមណ្ឌំ បរិតតំ មណ្ឌបេយ្យុំ បក្ខមមណ្ឌោ វីរិយិន្ទ្រិយំ កោសជ្ជំ កសរោ កោសជ្ជំ កសដំ ឆេត្វា វីរិយិន្ទ្រិយស្ស បក្ខមមណ្ឌំ បរិតតំ មណ្ឌ-បេយ្យុំ ឧបដ្ឋានមណ្ឌោ សតិន្ទ្រិយំ បមាទោ កស-រោ បមាទំ កសដំ ឆេត្វា សតិន្ទ្រិយស្ស ឧប-ដ្ឋានមណ្ឌំ បរិតតំ មណ្ឌបេយ្យុំ អវិក្ខេបមណ្ឌោ សមាធិន្ទ្រិយំ ឧទ្ធច្ចំ កសរោ ឧទ្ធច្ចំ កសដំ ឆេត្វា សមាធិន្ទ្រិយស្ស អវិក្ខេបមណ្ឌំ បរិតតំ

ព្រហ្មចរិយៈថា តើដូចម្តេច ? អរិយមគ្គមានអង្គ ៨ នេះឯង ។ ដូចម្តេចខ្លះ ? គឺសម្មាទិដ្ឋិ សម្មាសង្កប្បៈ សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ សម្មាវាយាមៈ សម្មាសតិ សម្មាសមាធិ នេះព្រហ្មចរិយៈថា ។

(๒) សទ្ធិន្ទ្រិយ ថ្វាដោយការជឿស៊ប់ អស្សទ្ធិយៈ (ការមិនជឿ) ជាកកវល្លក់ បុគ្គលលះចោល នូវអស្សទ្ធិយៈ ជាកកវល្លក់ ហើយក្រេបផឹកនូវធម្មជាតដ៏ថ្វាដោយការជឿស៊ប់ របស់សទ្ធិន្ទ្រិយ (ដោយព្រហ្មចរិយៈណា) ហេតុនោះ (ព្រហ្មចរិយៈនោះ) ឈ្មោះថាថ្វាគួរក្រេបផឹក វីរិយិន្ទ្រិយ ថ្វាដោយការផ្គងខ្នើន កោសជ្ជៈ ជាកកវល្លក់ បុគ្គលលះចោល នូវកោសជ្ជៈជាកកវល្លក់ ហើយក្រេបផឹកនូវធម្មជាតដ៏ថ្វាដោយការផ្គងខ្នើន របស់វីរិយិន្ទ្រិយ (ដោយព្រហ្មចរិយៈណា) ហេតុនោះ (ព្រហ្មចរិយៈនោះ) ឈ្មោះថាថ្វាគួរក្រេបផឹក សតិន្ទ្រិយ ថ្វាដោយការប្រុង បមាទៈ ជាកកវល្លក់ បុគ្គលលះចោល នូវបមាទៈ ជាកកវល្លក់ ហើយក្រេបផឹក នូវធម្មជាតដ៏ថ្វាដោយការប្រុង របស់សតិន្ទ្រិយ (ដោយព្រហ្មចរិយៈណា) ហេតុនោះ (ព្រហ្មចរិយៈនោះ) ឈ្មោះថាថ្វាគួរក្រេបផឹក សមាធិន្ទ្រិយ ថ្វាដោយការមិនរាយមាយ ឧទ្ធច្ចៈ ជាកកវល្លក់ បុគ្គលលះចោល នូវឧទ្ធច្ចៈជាកកវល្លក់ ហើយក្រេបផឹកនូវធម្មជាតដ៏ថ្វាដោយការមិនរាយមាយ របស់សមាធិន្ទ្រិយ (ដោយព្រហ្មចរិយៈណា) ហេតុនោះ (ព្រហ្មចរិយៈនោះ) ឈ្មោះថាថ្វាគួរក្រេបផឹក

មណ្ឌបេយ្យំ ឧស្សនមណ្ឌា បញ្ចង្គិយំ អវិជ្ជា កាស-
ជោ អវិជ្ជំ កាសដំ ជនេត្វា បញ្ចង្គិយស្ស ឧស្សន-
មណ្ឌំ បវត្តតិ មណ្ឌបេយ្យំ អស្សទ្ធិយេ អកម្មយ-
មណ្ឌា សទ្ធាពលំ អស្សទ្ធិយំ កាសជោ អស្សទ្ធិយំ
កាសដំ ជនេត្វា សទ្ធាពលស្ស អស្សទ្ធិយេ អកម្មយ-
មណ្ឌំ បវត្តតិ មណ្ឌបេយ្យំ កោសជ្ជេ អកម្ម-
យមណ្ឌា វីរិយពលំ កោសជ្ជំ កាសជោ កោសជ្ជំ
កាសដំ ជនេត្វា វីរិយពលស្ស កោសជ្ជេ អកម្មយ-
មណ្ឌំ បវត្តតិ មណ្ឌបេយ្យំ បមាទេ អកម្មយមណ្ឌា
សតិពលំ បមាទោ កាសជោ បមាទំ កាសដំ
ជនេត្វា សតិពលស្ស បមាទេ អកម្មយមណ្ឌំ បវត្តតិ

បញ្ចិន្ទ្រិយ ថ្លាដោយការយើញ អវិជ្ជាជាកកវល្លក់ បុគ្គលលះចោលនូវ
អវិជ្ជាជាកកវល្លក់ ហើយក្រេបផឹកនូវធម្មជាតដ៏ថ្លាដោយការយើញ របស់
បញ្ចិន្ទ្រិយ (ដោយព្រហ្មចរិយៈណា) ហេតុនោះ (ព្រហ្មចរិយនោះ)
ឈ្មោះថាថ្លាគួរក្រេបផឹក សទ្ធាពលៈ ថ្លាដោយការមិនញាប់ញ័រ ព្រោះ
ការមិនជឿ ការមិនជឿ ជាកកវល្លក់ បុគ្គលលះចោល នូវការមិនជឿ
ជាកកវល្លក់ ហើយក្រេបផឹកនូវធម្មជាតដ៏ថ្លា ដោយការមិនញាប់ញ័រ
ព្រោះធម្មជាតមិនជឿ របស់សទ្ធាពលៈ (ដោយព្រហ្មចរិយៈណា)
ហេតុនោះ (ព្រហ្មចរិយៈនោះ) ឈ្មោះថាថ្លាគួរក្រេបផឹក វីរិយពលៈ
ថ្លាដោយការមិនញាប់ញ័រ ព្រោះសេចក្តីខ្ជិល សេចក្តីខ្ជិល ជាកកវល្លក់
បុគ្គលលះចោល នូវសេចក្តីខ្ជិលជាកកវល្លក់ ហើយក្រេបផឹកនូវធម្មជាត
ដ៏ថ្លាដោយការមិនញាប់ញ័រ ព្រោះសេចក្តីខ្ជិល របស់វីរិយពលៈ (ដោយ
ព្រហ្មចរិយៈណា) ហេតុនោះ (ព្រហ្មចរិយៈនោះ) ឈ្មោះថាថ្លាគួរក្រេបផឹក
សតិពលៈ ថ្លាដោយការមិនញាប់ញ័រ ព្រោះបមាទៈ បមាទៈ ជាកក
វល្លក់ បុគ្គលលះចោលនូវបមាទៈជាកកវល្លក់ ហើយក្រេបផឹកនូវធម្មជាត
ដ៏ថ្លាដោយការមិនញាប់ញ័រព្រោះបមាទៈ របស់សតិពលៈ (ដោយព្រហ្ម-
ចរិយៈណា) ហេតុនោះ (ព្រហ្មចរិយៈនោះ) ឈ្មោះថាថ្លាគួរក្រេបផឹក

មណ្ឌបេយ្យំ ឧទ្ធុំ អកមវ្ហយមណ្ឌោ សមាធិពលំ
ឧទ្ធុំ កសដោ ឧទ្ធុំ កសដំ ឆឌ្ឌេត្វា សមាធិ-
ពលស្ស ឧទ្ធុំ អកមវ្ហយមណ្ឌំ បវត្តតិ មណ្ឌបេយ្យំ
អវិជ្ជាយ អកមវ្ហយមណ្ឌោ បញ្ញាពលំ អវិជ្ជា កស-
ដោ អវិជ្ជំ កសដំ ឆឌ្ឌេត្វា បញ្ញាពលស្ស អវិជ្ជាយ
អកមវ្ហយមណ្ឌំ បវត្តតិ មណ្ឌបេយ្យំ ឧបដ្ឋានមណ្ឌោ
សតិសម្ពោជ្ឈង្គោ បមាទោ សកដោ បមាទំ កសដំ
ឆឌ្ឌេត្វា សតិសម្ពោជ្ឈង្គស្ស ឧបដ្ឋានមណ្ឌំ បវ-
ត្តតិ មណ្ឌបេយ្យំ បរិចយមណ្ឌោ ឆម្ភវិចយសម្ពោ-
ជ្ឈង្គោ អវិជ្ជា កសដោ អវិជ្ជំ កសដំ ឆឌ្ឌេត្វា
ឆម្ភវិចយសម្ពោជ្ឈង្គស្ស បរិចយមណ្ឌំ បវត្តតិ

សមាធិពលៈ ថ្វាដោយការមិនញាប់ញ័រ ព្រោះទុច្ចរិតៈ ទុច្ចរិតៈ ជាកកិលេសអ្នក បុគ្គលលះចោល នូវទុច្ចរិតៈជាកកិលេសអ្នក ហើយត្រេកអរនូវធម្មជាតដ៏ថ្វា ដោយការមិនញាប់ញ័រព្រោះទុច្ចរិតៈ របស់សមាធិពលៈ (ដោយព្រហ្មចរិយៈណា) ហេតុនោះ (ព្រហ្មចរិយៈនោះ) ឈ្មោះថាថ្វាគួរត្រេកអរ បញ្ញាពលៈ ថ្វាដោយការមិនញាប់ញ័រព្រោះអវិជ្ជា អវិជ្ជាជាកកិលេសអ្នក បុគ្គលលះចោលនូវអវិជ្ជាជាកកិលេសអ្នក ហើយត្រេកអរនូវធម្មជាតដ៏ថ្វា ដោយការមិនញាប់ញ័រ ព្រោះអវិជ្ជា របស់បញ្ញាពលៈ (ដោយព្រហ្មចរិយៈណា) ហេតុនោះ (ព្រហ្មចរិយៈនោះ) ឈ្មោះថាថ្វាគួរត្រេកអរ សតិសម្ពោជ្ឈង្គ ថ្វាដោយការប្រុងប្រយ័ត្ន បមាទៈ ជាកកិលេសអ្នក បុគ្គលលះចោល នូវបមាទៈ ជាកកិលេសអ្នក ហើយត្រេកអរនូវធម្មជាតដ៏ថ្វា ដោយការប្រុងប្រយ័ត្ន របស់សតិសម្ពោជ្ឈង្គ (ដោយព្រហ្មចរិយៈណា) ហេតុនោះ (ព្រហ្មចរិយៈនោះ) ឈ្មោះថាថ្វាគួរត្រេកអរ ធម្មវិចយសម្ពោជ្ឈង្គ ថ្វាដោយការជ្រើសរើសធម៌ អវិជ្ជា ជាកកិលេសអ្នក បុគ្គលលះចោលនូវអវិជ្ជា ជាកកិលេសអ្នក ហើយត្រេកអរ នូវធម្មជាតដ៏ថ្វា ដោយការជ្រើសរើស របស់ធម្មវិចយសម្ពោជ្ឈង្គ (ដោយព្រហ្មចរិយៈណា) ហេតុនោះ (ព្រហ្មចរិយៈនោះ) ឈ្មោះថា ថ្វាគួរត្រេកអរ

មណ្ឌបេយ្យំ បក្ខហមណ្ឌោ វីរិយសម្ពោជ្ឈង្គោ
កោសជ្ជំ កសរោ កោសជ្ជំ កសំ ឆឌ្ឌេត្វា
វីរិយសម្ពោជ្ឈង្គំសរ្ប បក្ខហមណ្ឌំ បរិតតិ មណ្ឌបេយ្យំ
ជរណមណ្ឌោ បីតិសម្ពោជ្ឈង្គោ បរិឌ្ឌាហោ កសរោ
បរិឌ្ឌាហំ កសំ ឆឌ្ឌេត្វា បីតិសម្ពោជ្ឈង្គំសរ្ប
ជរណមណ្ឌំ បរិតតិ មណ្ឌបេយ្យំ ឧបសមមណ្ឌោ
បស្សទ្ធិសម្ពោជ្ឈង្គោ ទុដ្ឋុល្លំ កសរោ ទុដ្ឋុល្លំ
កសំ ឆឌ្ឌេត្វា បស្សទ្ធិសម្ពោជ្ឈង្គំសរ្ប ឧបសម-
មណ្ឌំ បរិតតិ មណ្ឌបេយ្យំ អរិក្ខេបមណ្ឌោ សមា-
ធិសម្ពោជ្ឈង្គោ ទុទ្ធច្ចំ កសរោ ទុទ្ធច្ចំ កសំ
ឆឌ្ឌេត្វា សមាធិសម្ពោជ្ឈង្គំសរ្ប អរិក្ខេបមណ្ឌំ បរិតតិ

វីរិយសម្ពោជ្ឈង្គ ថ្វាដោយការផ្គងខ្នើង សេចក្តីឱ្យលជាតកវល្អក់ បុគ្គលលះចោល នូវសេចក្តីឱ្យល ជាតកវល្អក់ ហើយក្រេបផឹកនូវធម្មជាតដ៏ថ្លា ដោយការផ្គងខ្នើយ របស់វីរិយសម្ពោជ្ឈង្គ (ដោយព្រហ្មចរិយៈណា) ហេតុនោះ (ព្រហ្មចរិយៈនោះ) ឈ្មោះថាថ្លាគួរក្រេបផឹក បីតិសម្ពោជ្ឈង្គ ថ្លាដោយការផ្អួយ សេចក្តីក្តៅក្រហាយជាតកវល្អក់ បុគ្គលលះចោលនូវសេចក្តីក្តៅក្រហាយ ជាតកវល្អក់ ហើយក្រេបផឹក នូវធម្មជាតដ៏ថ្លា ដោយការផ្អួយ របស់បីតិសម្ពោជ្ឈង្គ (ដោយព្រហ្មចរិយៈណា) ហេតុនោះ (ព្រហ្មចរិយៈនោះ) ឈ្មោះថាថ្លាគួរក្រេបផឹក បស្សទ្ធិសម្ពោជ្ឈង្គ ថ្លាដោយការស្ងប់រម្ងាប់ ធម្មជាតជាទីតាំងនៃសេចក្តីអាក្រក់ ជាតកវល្អក់ បុគ្គលលះចោល នូវធម្មជាតជាទីតាំង នៃសេចក្តីអាក្រក់ ជាតកវល្អក់ ហើយក្រេបផឹកនូវធម្មជាតដ៏ថ្លា ដោយការស្ងប់ របស់បស្សទ្ធិសម្ពោជ្ឈង្គ (ដោយព្រហ្មចរិយៈណា) ហេតុនោះ (ព្រហ្មចរិយៈនោះ) ឈ្មោះថាថ្លាគួរក្រេបផឹក សមាធិសម្ពោជ្ឈង្គ ថ្លាដោយការមិនពយមាយ ចិត្តៈ ជាតកវល្អក់ បុគ្គលលះចោលនូវចិត្តៈជាតកវល្អក់ ហើយក្រេបផឹកនូវធម្ម-ជាតដ៏ថ្លាដោយការមិនពយមាយ របស់សមាធិសម្ពោជ្ឈង្គ (ដោយព្រហ្ម-ចរិយៈណា) ហេតុនោះ (ព្រហ្មចរិយៈនោះ) ឈ្មោះថាថ្លាគួរក្រេបផឹក

មណ្ឌបេយ្យំ បដិសង្ខានមណ្ឌោ ឧបេក្ខាសម្ពោជ្ឈង្គោ
អប្បដិសង្ខានំ កាសដោ អប្បដិសង្ខានំ កាសដំ
ឆឌ្ឌេត្វា ឧបេក្ខាសម្ពោជ្ឈង្គស្ស បដិសង្ខានមណ្ឌំ
បិវតីតំ មណ្ឌបេយ្យំ ឧស្សន្នមណ្ឌោ សម្មាទិដ្ឋិ
មិច្ឆាទិដ្ឋិ កាសដោ មិច្ឆាទិដ្ឋិ កាសដំ ឆឌ្ឌេត្វា
សម្មាទិដ្ឋិយោ ឧស្សន្នមណ្ឌំ បិវតីតំ មណ្ឌបេយ្យំ
អកិរេបនមណ្ឌោ សម្មាសង្កប្បោ មិច្ឆាសង្កប្បោ
កាសដោ មិច្ឆាសង្កប្បំ កាសដំ ឆឌ្ឌេត្វា សម្មាសង្ក-
ប្បស្ស អកិរេបនមណ្ឌំ បិវតីតំ មណ្ឌបេយ្យំ បរិក្ក-
ហាមណ្ឌោ សម្មាវាចា មិច្ឆាវាចា កាសដោ មិច្ឆាវាចំ
កាសដំ ឆឌ្ឌេត្វា សម្មាវាចាយ បរិក្កហាមណ្ឌំ បិវតីតំ

ចេតោសមោដ្ឋង្គ ថ្វាដោយការរំពឹង ការមិនរំពឹង ជាកកិលេស បុគ្គលលះចោល នូវការមិនរំពឹងជាកកិលេស ហើយក្រេបផឹកនូវធម្មជាតដ៏ថ្លា ដោយការរំពឹង របស់ចេតោសមោដ្ឋង្គ (ដោយព្រហ្មចរិយៈណា) ហេតុនោះ (ព្រហ្មចរិយៈនោះ) ឈ្មោះថា ថ្លាគួរក្រេបផឹក សម្មាទិដ្ឋិ ថ្លាដោយការឃើញ មិច្ឆាទិដ្ឋិ ជាកកិលេស បុគ្គលលះចោលនូវមិច្ឆាទិដ្ឋិជាកកិលេស ហើយក្រេបផឹកនូវធម្មជាតដ៏ថ្លា ដោយការឃើញរបស់សម្មាទិដ្ឋិ (ដោយព្រហ្មចរិយៈណា) ហេតុនោះ (ព្រហ្មចរិយៈនោះ) ឈ្មោះថាថ្លាគួរក្រេបផឹក សម្មាសង្កប្បៈ ថ្លាដោយការលើកចិត្តទៅដើម (កាន់អារម្មណ៍) មិច្ឆាសង្កប្បៈ ជាកកិលេស បុគ្គលលះចោលនូវមិច្ឆាសង្កប្បៈជាកកិលេស ហើយក្រេបផឹកនូវធម្មជាតដ៏ថ្លា ដោយការលើកចិត្តទៅដើម របស់សម្មាសង្កប្បៈ (ដោយព្រហ្មចរិយៈណា) ហេតុនោះ (ព្រហ្មចរិយៈនោះ) ឈ្មោះថាថ្លាគួរក្រេបផឹក សម្មាវាចា ថ្លាដោយការកំណត់ មិច្ឆាវាចាជាកកិលេស បុគ្គលលះចោល នូវមិច្ឆាវាចាជាកកិលេស ហើយក្រេបផឹកនូវធម្មជាតដ៏ថ្លា ដោយការកំណត់ របស់សម្មាវាចា (ដោយព្រហ្មចរិយៈណា) ហេតុនោះ (ព្រហ្មចរិយៈនោះ) ឈ្មោះថាថ្លាគួរក្រេបផឹក

មណ្ឌបេយ្យំ សមុដ្ឋានមណ្ឌោ សម្មាកម្មន្តោ មិច្ឆាកម្ម-
ន្តោ កាសដោ មិច្ឆាកម្មន្តំ កាសដំ ឆឌ្ឌេត្វា សម្មាកម្ម-
ន្តស្ស សមុដ្ឋានមណ្ឌំ បិវតីតំ មណ្ឌបេយ្យំ ភេជ្ជាន-
មណ្ឌោ សម្មាអាជីវោ មិច្ឆាអាជីវោ កាសដោ មិច្ឆា-
អាជីវំ កាសដំ ឆឌ្ឌេត្វា សម្មាអាជីវស្ស ភេជ្ជានមណ្ឌំ
បិវតីតំ មណ្ឌបេយ្យំ បក្ខហមណ្ឌោ សម្មាវាយាមោ
មិច្ឆាវាយាមោ កាសដោ មិច្ឆាវាយាមំ កាសដំ ឆឌ្ឌេត្វា
សម្មាវាយាមស្ស បក្ខហមណ្ឌំ បិវតីតំ មណ្ឌបេយ្យំ ឧប-
ដ្ឋានមណ្ឌោ សម្មាសតិ មិច្ឆាសតិ កាសដោ មិច្ឆាសតិ
កាសដំ ឆឌ្ឌេត្វា សម្មាសតិយា ឧបដ្ឋានមណ្ឌំ បិវតីតំ

សម្មាកម្មន្តៈ ថ្វាយដោយការខ្នះខ្នែង មិច្ឆាកម្មន្តៈ ជាកតវល្អក់ បុគ្គលលះចោល នូវមិច្ឆាកម្មន្តៈ ជាកតវល្អក់ ហើយក្រេបផឹកនូវធម្មជាតដ៏ថ្លា ដោយការខ្នះខ្នែង របស់សម្មាកម្មន្តៈ (ដោយព្រហ្មចរិយៈណា) ហេតុនោះ (ព្រហ្មចរិយៈនោះ) ឈ្មោះថាថ្លាគួរក្រេបផឹក សម្មាអាជីវៈ ថ្វាយដោយសេចក្តីផ្សព្វផង់ មិច្ឆាអាជីវៈ ជាកតវល្អក់ បុគ្គលលះចោលនូវមិច្ឆាអាជីវៈ ជាកតវល្អក់ ហើយក្រេបផឹកនូវធម្មជាតដ៏ថ្លា ដោយសេចក្តីផ្សព្វផង់ របស់សម្មាអាជីវៈ (ដោយព្រហ្មចរិយៈណា) ហេតុនោះ (ព្រហ្មចរិយៈនោះ) ឈ្មោះថាថ្លាគួរក្រេបផឹក សម្មាវាយាមៈ ថ្វាយដោយការផ្គងខ្នើង មិច្ឆាវាយាមៈ ជាកតវល្អក់ បុគ្គលលះចោលនូវមិច្ឆាវាយាមៈ ជាកតវល្អក់ ហើយក្រេបផឹកនូវធម្មជាតដ៏ថ្លា ដោយការផ្គងខ្នើង របស់សម្មាវាយាមៈ (ដោយព្រហ្មចរិយៈណា) ហេតុនោះ (ព្រហ្មចរិយៈនោះ) ឈ្មោះថាថ្លាគួរក្រេបផឹក សម្មាសតិ ថ្វាយដោយការប្រុងប្រៀង មិច្ឆាសតិ ជាកតវល្អក់ បុគ្គលលះចោល នូវមិច្ឆាសតិជាកតវល្អក់ ហើយក្រេបផឹក នូវធម្មជាតដ៏ថ្លា ដោយការប្រុងប្រៀង របស់សម្មាសតិ (ដោយព្រហ្មចរិយៈណា) ហេតុនោះ (ព្រហ្មចរិយៈនោះ) ឈ្មោះថា ថ្លាគួរក្រេបផឹក

មណ្ឌោបេយ្យំ អរិយេ្ចបមណ្ឌោ សម្ភាសមាធិ មិច្ឆា-
សមាធិ កាសដោ មិច្ឆាសមាធិ កាសដំ ឆេ្ចត្វា
សម្ភាសមាធិស្ស អរិយេ្ចបមណ្ឌំ បិវតីតំ មណ្ឌោបេយ្យំ ។

(៣) អត្ថំ មណ្ឌោ អត្ថំ បេយ្យំ អត្ថំ កា-
សដោ អធិមោក្ខមណ្ឌោ សទ្ធិន្ទ្រិយំ អស្សទ្ធិយំ
កាសដោ យោ តត្ថ អត្ថរសោ ឆម្មរសោ វិមុត្តិ-
រសោ ឥធំ បេយ្យំ បក្ខហមណ្ឌោ វីរិយិន្ទ្រិយំ កោ-
សជ្ជំ កាសដោ យោ តត្ថ អត្ថរសោ ឆម្មរសោ
វិមុត្តិរសោ ឥធំ បេយ្យំ ឧបដ្ឋាឧមណ្ឌោ សតិន្ទ្រិយំ
បមាដោ កាសដោ យោ តត្ថ អត្ថរសោ ឆម្មរសោ
វិមុត្តិរសោ ឥធំ បេយ្យំ អរិយេ្ចបមណ្ឌោ សមាធិន្ទ្រិយំ
ឧទ្ធច្ចំ កាសដោ យោ តត្ថ អត្ថរសោ ឆម្មរសោ
វិមុត្តិរសោ ឥធំ បេយ្យំ ឧសុ្សទមណ្ឌោ បញ្ញិន្ទ្រិយំ អវិជ្ជា
កាសដោ យោ តត្ថ អត្ថរសោ ឆម្មរសោ វិមុត្តិរសោ

សម្មាសមាធិ ថ្លាដោយការមិនរាយមាយ មិច្ឆាសមាធិ ជាតកវល្អក់ បុគ្គលលះចោលនូវមិច្ឆាសមាធិ ជាតកវល្អក់ ហើយក្រេបផឹកនូវធម្មជាតដ៏ថ្លាដោយការមិនរាយមាយ របស់សម្មាសមាធិ (ដោយព្រហ្មចរិយៈណា) ហេតុនោះ (ព្រហ្មចរិយៈនោះ) ឈ្មោះថាថ្លាគួរក្រេបផឹក ។

(៣) សេចក្តីថ្លាក៏មាន ធម្មជាតគួរក្រេបផឹកក៏មាន សភាពកវល្អក់ក៏មាន សទ្ធិន្ទ្រិយ ថ្លាដោយការជឿ ការមិនជឿ ជាតកវល្អក់ របស់នៃអត្ត របស់នៃធម៌ របស់នៃវិមុត្តិ ក្នុងសទ្ធិន្ទ្រិយនោះ ឯណា នេះជាធម្មជាតគួរក្រេបផឹក វីរិយិន្ទ្រិយ ថ្លាដោយការផ្គងឆ្អឺងឆ្អៀង សេចក្តីខ្ជិល ជាតកវល្អក់ របស់នៃអត្ត របស់នៃធម៌ របស់នៃវិមុត្តិ ក្នុងវីរិយិន្ទ្រិយនោះ ឯណា នេះជាធម្មជាតគួរក្រេបផឹក សតិន្ទ្រិយថ្លាដោយការប្រុងប្រយ័ត្ន ជាតកវល្អក់ របស់នៃអត្ត របស់នៃធម៌ របស់នៃវិមុត្តិ ក្នុងសតិន្ទ្រិយនោះ ឯណា នេះជាធម្មជាតគួរក្រេបផឹក សមាធិន្ទ្រិយ ថ្លាដោយការមិនរាយមាយ ទន្ទួច ជាតកវល្អក់ របស់នៃអត្ត របស់នៃធម៌ របស់នៃវិមុត្តិ ក្នុងសមាធិន្ទ្រិយនោះ ឯណា នេះជាធម្មជាតគួរក្រេបផឹក បញ្ញិន្ទ្រិយ ថ្លាដោយការយើញ អវិជ្ជា ជាតកវល្អក់ របស់នៃអត្ត របស់នៃធម៌ របស់នៃវិមុត្តិ ក្នុងបញ្ញិន្ទ្រិយនោះ ឯណា នេះជាធម្មជាតគួរក្រេបផឹក

៥ធំ បេយ្យំ អសង្ខ្យេយ្យេ អកម្បិយមណ្ឌោ សង្ខ្យាពលំ
អសង្ខ្យេយ្យំ កាសជោ យោ តត្ត អត្តរាសោ ធម្មរាសោ
វិមុត្តិរាសោ ៥ធំ បេយ្យំ តោសឡ្ឍេ អកម្បិយមណ្ឌោ
វីរិយពលំ តោសឡ្ឍំ កាសជោ យោ តត្ត អត្តរាសោ
ធម្មរាសោ វិមុត្តិរាសោ ៥ធំ បេយ្យំ បមាណេ អកម្បិយម-
ណ្ឌោ សតិពលំ បមាណោ កាសជោ យោ តត្ត អត្ត-
រាសោ ធម្មរាសោ វិមុត្តិរាសោ ៥ធំ បេយ្យំ ឧទ្ធច្ចេ អ-
កម្បិយមណ្ឌោ សមាធិពលំ ឧទ្ធច្ចំ កាសជោ យោ
តត្ត អត្តរាសោ ធម្មរាសោ វិមុត្តិរាសោ ៥ធំ បេយ្យំ
អវិជ្ជាយ អកម្បិយមណ្ឌោ បញ្ញាពលំ អវិជ្ជា កាស-
ជោ យោ តត្ត អត្តរាសោ ធម្មរាសោ វិមុត្តិរាសោ ៥ធំ
បេយ្យំ ឧបដ្ឋានមណ្ឌោ សតិសម្ពោជ្ឈង្គោ បមាណោ កា-
សជោ យោ តត្ត អត្តរាសោ ធម្មរាសោ វិមុត្តិរាសោ ៥ធំ
បេយ្យំ បវិចយមណ្ឌោ ធម្មវិចយសម្ពោជ្ឈង្គោ អវិជ្ជា
កាសជោ យោ តត្ត អត្តរាសោ ធម្មរាសោ វិមុត្តិរាសោ

សទ្ធាពលៈ ថ្វាដោយការមិនញាប់ញ័រព្រោះការមិនជឿ ការមិនជឿជាកកវល្អក់ រសៃនៃអត្ត រសៃនៃធម៌ រសៃនៃវិមុត្តិ ក្នុងសទ្ធាពលៈនោះឯណា នេះជាធម្មជាតគួរក្រេបផឹក វីរិយពលៈ ថ្វាដោយការមិនញាប់ញ័រព្រោះសេចក្តីខ្ជិល សេចក្តីខ្ជិលជាកកវល្អក់ រសៃនៃអត្ត រសៃនៃធម៌ រសៃនៃវិមុត្តិ ក្នុងវីរិយពលៈនោះ ឯណា នេះជាធម្មជាតគួរក្រេបផឹក សតិពលៈ ថ្វាដោយការមិនញាប់ញ័រ ព្រោះបមាទៈ បមាទៈជាកកវល្អក់ រសៃនៃអត្ត រសៃនៃធម៌ រសៃនៃវិមុត្តិ ក្នុងសតិពលៈនោះ ឯណា នេះជាធម្មជាតគួរក្រេបផឹក សមាធិពលៈ ថ្វាដោយការមិនញាប់ញ័រព្រោះឧទ្ធច្ចៈ ឧទ្ធច្ចៈ ជាកកវល្អក់ រសៃនៃអត្ត រសៃនៃធម៌ រសៃនៃវិមុត្តិ ក្នុងសមាធិពលៈនោះ ឯណា នេះជាធម្មជាតគួរក្រេបផឹក បញ្ញាពលៈ ថ្វាដោយការមិនញាប់ញ័រ ព្រោះអវិជ្ជា អវិជ្ជា ជាកកវល្អក់ រសៃនៃអត្ត រសៃនៃធម៌ រសៃនៃវិមុត្តិ ក្នុងបញ្ញាពលៈនោះ ឯណា នេះជាធម្មជាតគួរក្រេបផឹក សតិសម្ពោជ្ឈង្គ ថ្វាដោយការប្រុងបមាទៈជាកកវល្អក់ រសៃនៃអត្ត រសៃនៃធម៌ រសៃនៃវិមុត្តិ ក្នុងសតិសម្ពោជ្ឈង្គនោះ ឯណា នេះជាធម្មជាតគួរក្រេបផឹក ធម្មវិចយសម្ពោជ្ឈង្គ ថ្វាដោយការជ្រើសរើសធម៌ អវិជ្ជា ជាកកវល្អក់ រសៃនៃអត្ត រសៃនៃធម៌ រសៃនៃវិមុត្តិ ក្នុងធម្មវិចយសម្ពោជ្ឈង្គនោះ ឯណា នេះជាធម្មជាតគួរក្រេបផឹក

สนฺติ ปเนว ปคฺคหามเนฺตฺยปิ วิริยสมฺโพชฺฌงฺโค. สมฺปหฏฺฐา กาสเวา ยาว สตฺต อสฺสวา ธมฺมสวา วิมุตฺติสวา สนฺติ ปเนว ปสฺสทฺธามเนฺตฺยปิ ปสฺสทฺธิสมฺโพชฺฌงฺโค. อุปสมมเนฺตฺยปิ อุปสมสมฺโพชฺฌงฺโค. สมาธิมเนฺตฺยปิ สมาธิสมฺโพชฺฌงฺโค. อาเนฺตฺยปิ อาเนฺตฺยสมฺโพชฺฌงฺโค. ปฏิสงฺขามเนฺตฺยปิ ปฏิสงฺขานมเนฺตฺยปิ อุเปกฺขาสมฺโพชฺฌงฺโค. อปฺปฏิสงฺขานมเนฺตฺยปิ[1] กาสเวา ยาว สตฺต อสฺสวา ธมฺมสวา วิมุตฺติสวา สนฺติ ปเนว ฯ

(๔) ทสฺสนมเนฺตฺยปิ สมฺมาทิฏฺฐิ มิจฺฉาทิฏฺฐิ กาสเวา ยาว สตฺต อสฺสวา ธมฺมสวา วิมุตฺติสวา สนฺติ ปเนว อภิเนฺตฺยปิ อภินมเนฺตฺยปิ สมฺมาสงฺกปฺโป มิจฺฉาสงฺกปฺโป กาสเวา ยาว สตฺต อสฺสวา ธมฺมสวา วิมุตฺติสวา

---

๑ ม. อปฺปฏิสงฺขา ฯ

វីរិយសម្ពោជ្ឈង្គ ថ្វាដោយការផ្គងខ្នើង សេចក្តីឱ្យលជាកកល្អក់ រសនៃអត្ត រសនៃធម៌ រសនៃវិមុត្តិ ក្នុងវីរិយសម្ពោជ្ឈង្គនោះ ឯណា នេះជាធម្មជាតគួរក្រេបផឹក បីតិសម្ពោជ្ឈង្គ ថ្វាដោយការផ្សាយទៅ សេចក្តីក្តៅក្រហាយ ជាតកកល្អក់ រសនៃអត្ត រសនៃធម៌ រសនៃវិមុត្តិ ក្នុងបីតិសម្ពោជ្ឈង្គនោះ ឯណា នេះជាធម្មជាតគួរក្រេបផឹក បស្សទ្ធិសម្ពោជ្ឈង្គ ថ្វាដោយការស្ងប់ ធម្មជាតជាទីតាំងនៃសេចក្តីអាក្រក់ ជាតកកល្អក់ រសនៃអត្ត រសនៃធម៌ រសនៃវិមុត្តិ ក្នុងបស្សទ្ធិសម្ពោជ្ឈង្គនោះ ឯណា នេះជាធម្មជាតគួរក្រេបផឹក សមាធិសម្ពោជ្ឈង្គ ថ្វាដោយការមិនពយមាយ ទន្ទួលជាកកល្អក់ រសនៃអត្ត រសនៃធម៌ រសនៃវិមុត្តិ ក្នុងសមាធិសម្ពោជ្ឈង្គនោះ ឯណា នេះជាធម្មជាតគួរក្រេបផឹក ឧបេក្ខាសម្ពោជ្ឈង្គ ថ្វាដោយការទឹកពំងឹ ការមិនទឹកពំងឹ ជាតកកល្អក់ រសនៃអត្ត រសនៃធម៌ រសនៃវិមុត្តិ ក្នុងឧបេក្ខាសម្ពោជ្ឈង្គនោះ ឯណា នេះជាធម្មជាតគួរក្រេបផឹក ។

(៤) សម្មាទិដ្ឋិ ថ្វាដោយការឃើញ មិច្ឆាទិដ្ឋិ ជាតកកល្អក់ រសនៃអត្ត រសនៃធម៌ រសនៃវិមុត្តិ ក្នុងសម្មាទិដ្ឋិនោះ ឯណា នេះជាធម្មជាតគួរក្រេបផឹក សម្មាសង្កប្ប: ថ្វាដោយការលើកចិត្តទៅ (កាន់អារម្មណ៍) មិច្ឆាសង្កប្ប: ជាតកកល្អក់ រសនៃអត្ត រសនៃធម៌ រសនៃវិមុត្តិ ក្នុងសម្មាសង្កប្ប:នោះ ឯណា នេះជាធម្មជាតគួរក្រេបផឹក

สนฺธิ เปยฺยำ อวิกฺขมฺภนมณฺฑนา สมฺมาทิฏฺฐิ มิจฺฉาทิฏฺฐิ กาสา-
ยนฺโต ยาว ตตฺถ อตฺถาสา ธมฺมาสา วิมุตฺติยาสา สนฺธิ
เปยฺยำ สมุฏฺฐานมณฺฑนา สมฺมากมฺมนฺโต มิจฺฉากมฺมนฺโต
กาสายนฺโต ยาว ตตฺถ อตฺถาสา ธมฺมาสา วิมุตฺติยาสา
สนฺธิ เปยฺยำ เวทนามณฺฑนา สมฺมาอาชีโว มิจฺฉาอาชีโว
กาสายนฺโต ยาว ตตฺถ อตฺถาสา ธมฺมาสา วิมุตฺติยาสา สนฺธิ
เปยฺยำ ปกฺขนฺทนมณฺฑนา สมฺมาวายาโม มิจฺฉาวายาโม
กาสายนฺโต ยาว ตตฺถ อตฺถาสา ธมฺมาสา วิมุตฺติยาสา
สนฺธิ เปยฺยำ อุปฏฺฐานมณฺฑนา สมฺมาสติ มิจฺฉาสติ
กาสายนฺโต ยาว ตตฺถ อตฺถาสา ธมฺมาสา วิมุตฺติ-
ยาสา สนฺธิ เปยฺยำ อวิกฺเขปมณฺฑนา สมฺมาสมาธิ
มิจฺฉาสมาธิ กาสายนฺโต ยาว ตตฺถ อตฺถาสา ธมฺม-
ยาสา วิมุตฺติยาสา สนฺธิ เปยฺยำ ญาณมณฺฑนา
สมฺมาญาณ อกิเลสมณฺฑนา สมฺมาสงฺกปฺปา ปวิกฺข-
ยามณฺฑนา สมฺมาวาจา สมุฏฺฐานมณฺฑนา สมฺมากม-
มนฺโต เวทนามณฺฑนา สมฺมาอาชีโว ปกฺขนฺทนมณฺฑนา

សម្មាវាចា ថ្លាដោយការតំណត់ខុក មិច្ឆាវាចា ជាកកវល្អក់ រសនៃអត្ត
រសនៃធម៌ រសនៃវិមុត្តិ ក្នុងសម្មាវាចានោះ ឯណា នេះជាធម្មជាតគួរ
ក្រែបធឹក. សម្មាកម្មន: ថ្លាដោយការខ្នះខ្នែង មិច្ឆាកម្មន: ជាកកវល្អក់
រសនៃអត្ត រសនៃធម៌ រសនៃវិមុត្តិ ក្នុងសម្មាកម្មន:នោះ ឯណា នេះ
ជាធម្មជាតគួរក្រែបធឹក សម្មាអាជីវ: ថ្លាដោយសេចក្តីបរិសុទ្ធិ មិច្ឆាអាជីវ:
ជាកកវល្អក់ រសនៃអត្ត រសនៃធម៌ រសនៃវិមុត្តិ ក្នុងសម្មាអាជីវ:នោះ
ឯណា នេះជាធម្មជាតគួរក្រែបធឹក សម្មាវាយាម: ថ្លាដោយការផ្គង់ឡើង
មិច្ឆាវាយាម: ជាកកវល្អក់ រសនៃអត្ត រសនៃធម៌ រសនៃវិមុត្តិកង់សម្មា-
វាយាម:នោះ ឯណា នេះជាធម្មជាតគួរក្រែបធឹក សម្មាសតិ ថ្លាដោយ
ការប្រុង មិច្ឆាសតិ ជាកកវល្អក់ រសនៃអត្ត រសនៃធម៌ រសនៃវិមុត្តិ
កង់សម្មាសតិនោះ ឯណា នេះជាធម្មជាតគួរក្រែបធឹក សម្មាសមាធិ ថ្លា
ដោយការមិនពយមាយ មិច្ឆាសមាធិ ជាកកវល្អក់ រសនៃអត្ត រសនៃធម៌
រសនៃវិមុត្តិ ក្នុងសម្មាសមាធិនោះ ឯណា នេះជាធម្មជាតគួរក្រែបធឹក
សម្មាទិដ្ឋិ ថ្លាដោយការយើញ សម្មាសង្កប្ប: ថ្លាដោយការលើកចិត្ត
ឡើង (កាន់អារម្មណ៍) សម្មាវាចា ថ្លាដោយការតំណត់ សម្មាកម្-
ន្ត: ថ្លាដោយការខ្នះខ្នែង សម្មាអាជីវ: ថ្លាដោយសេចក្តីបរិសុទ្ធិ

សម្មាកាយាមោ ឧបដ្ឋានមណ្ឌោ សម្មាសតិ អវិក្ខេប-
មណ្ឌោ សម្មាសមាធិ ឧបដ្ឋានមណ្ឌោ សតិសម្ពោជ្ឈង្គោ
បវិចយមណ្ឌោ ធម្មវិចយសម្ពោជ្ឈង្គោ បក្ខហមណ្ឌោ
វីរិយសម្ពោជ្ឈង្គោ ផរណមណ្ឌោ បីតិសម្ពោជ្ឈង្គោ
ឧបសមមណ្ឌោ បស្សទ្ធិសម្ពោជ្ឈង្គោ អវិក្ខេបម-
ណ្ឌោ សមាធិសម្ពោជ្ឈង្គោ បដិសង្ខានមណ្ឌោ ឧ-
បេក្ខាសម្ពោជ្ឈង្គោ អសទ្ធិយេ អកម្បិយមណ្ឌោ
សទ្ធាពលំ កោសជ្ជេ អកម្បិយមណ្ឌោ វីរិយពលំ
បមាទេ អកម្បិយមណ្ឌោ សតិពលំ ឧទ្ធច្ចេ អកម្បិ-
យមណ្ឌោ សមាធិពលំ អវិជ្ជាយ អកម្បិយមណ្ឌោ
បញ្ញាពលំ អធិមោក្ខមណ្ឌោ សទ្ធិន្ទ្រិយំ បក្ខហមណ្ឌោ
វីរិយិន្ទ្រិយំ ឧបដ្ឋានមណ្ឌោ សតិន្ទ្រិយំ អវិក្ខេបមណ្ឌោ
សមាធិន្ទ្រិយំ ទស្សនមណ្ឌោ បញ្ញិន្ទ្រិយំ អាធិបតេយ្យ-
ដ្ឋេន ឥន្ទ្រិយំ(១) មណ្ឌោ អកម្បិយដ្ឋេន ពលំ(២)អណ្ឌោ
និយ្យានដ្ឋេន ពោជ្ឈង្គោ មណ្ឌោ ហេតុដ្ឋេន មគ្គោ ម-
ណ្ឌោ ឧបដ្ឋានដ្ឋេន សតិបដ្ឋានា មណ្ឌោ បធានដ្ឋេន

---

១ ម. អិន្ទ្រិយោ ។ ២ ម. ពលា ។

សម្មាវាយាម: ថ្វាដោយការផ្គងខ្នើង សម្មាសតិ ថ្វាដោយការប្រុង
សម្មាសមាធិ ថ្វាដោយការមិនពយមាយ សតិសម្ពោជ្ឈង្គ ថ្វាដោយ
ការប្រុង ធម្មវិចយសម្ពោជ្ឈង្គ ថ្វាដោយការជ្រើសរើសធម៌ វីរិយស-
ម្ពោជ្ឈង្គ ថ្វាដោយការផ្គងខ្នើង បីតិសម្ពោជ្ឈង្គ ថ្វាដោយការផ្សាយ
ទៅ បស្សទ្ធិសម្ពោជ្ឈង្គ ថ្វាដោយការស្ងប់ សមាធិសម្ពោជ្ឈង្គ ថ្វា
ដោយការមិនពយមាយ ឧបេក្ខាសម្ពោជ្ឈង្គ ថ្វាដោយការនឹកវាងឆ
សទ្ធាពល: ថ្វាដោយការមិនញាប់ញ័រ ព្រោះការមិនជឿ វីរិយពល: ថ្វា
ដោយការមិនញាប់ញ័រ ព្រោះសេចក្តីខ្ជិល សតិពល: ថ្វាដោយការ
មិនញាប់ញ័រ ព្រោះបមាទ: សមាធិពល: ថ្វាដោយការមិនញាប់ញ័រ
ព្រោះឧទ្ធច្ច: បញ្ញាពល: ថ្វាដោយការមិនញាប់ញ័រ ព្រោះអវិជ្ជា
សទ្ធិន្ទ្រិយ ថ្វាដោយការជឿសិប់ វីរិយិន្ទ្រិយ ថ្វាដោយការផ្គងខ្នើង
សតិន្ទ្រិយ ថ្វាដោយការប្រុង សមាធិន្ទ្រិយ ថ្វាដោយការមិនពយមាយ
បញ្ញិន្ទ្រិយ ថ្វាដោយការឃើញ ឥន្ទ្រិយ ថ្វាដោយអត្ថថាជាអធិបតី
ពល: ថ្វាដោយអត្ថថាមិនញាប់ញ័រ ពោជ្ឈង្គ ថ្វាដោយអត្ថថាចេញចាក
(វដ្ត:) មគ្គ ថ្វាដោយអត្ថថាជាហេតុ សតិប្បដ្ឋាន ថ្វាដោយអត្ថថាប្រុង

សម្ពុទ្ធានញ្ច មណ្ឌោ ឥជ្ឈនដ្ឋេន ឥទ្ធិយា មណ្ឌោ អវិ-
ក្ខេបដ្ឋេន សមថោ មណ្ឌោ អនុបស្សនដ្ឋេន វិបស្សនា
មណ្ឌោ ឯករសដ្ឋេន សមថវិបស្សនា មណ្ឌោ អនតិវត្ត-
នដ្ឋេន យុគនទ្ធា មណ្ឌោ សំវរដ្ឋេន សីលវិសុទ្ធិ មណ្ឌោ
អវិក្ខេបដ្ឋេន ចិត្តវិសុទ្ធិ មណ្ឌោ ទស្សនដ្ឋេន ទិដ្ឋ-
វិសុទ្ធិ មណ្ឌោ មុត្តដ្ឋេន វិមោក្ខោ មណ្ឌោ បដិវេធដ្ឋេន
វិជ្ជា មណ្ឌោ បរិច្ចាគដ្ឋេន វិមុត្តិ មណ្ឌោ សមុច្ឆេទ-
ដ្ឋេន ខយេ ញាណំ មណ្ឌោ បដិប្បស្សទ្ធដ្ឋេន អនុ-
ប្បាទេ ញាណំ មណ្ឌោ ឆន្ទោ មូលដ្ឋេន មណ្ឌោ
មនសិការោ សមុដ្ឋានដ្ឋេន មណ្ឌោ ផស្សោ សមោ-
ធានដ្ឋេន មណ្ឌោ វេទនា សមោសរណដ្ឋេន មណ្ឌោ
សមាធិ បមុខដ្ឋេន មណ្ឌោ សតិ អាធិបតេយ្យដ្ឋេន
មណ្ឌោ បញ្ញា តត្តុត្តរដ្ឋេន មណ្ឌោ វិមុត្តិ សារដ្ឋេន
មណ្ឌោ អមតោគធំ និព្វានំ បរិយោសានដ្ឋេន
មណ្ឌោតិ ។

មណ្ឌបេយ្យកថា ។

ភាណវារំ ។

មហាវគ្គោ បឋមោ ។

សម្មប្បធាន ថ្វាយដោយអត្ថថាតំកល់ទុក ឥទ្ធិបាទ ថ្វាយដោយអត្ថថាសម្រេចសមថៈ ថ្វាយដោយអត្ថថាមិនពយមាយ វិបស្សនា ថ្វាយដោយអត្ថថាឃើញរឿយៗ សមថៈនិងវិបស្សនា ថ្វាយដោយអត្ថថាមានរសតែមួយ ធម៌ដែលជាប់គ្នាជាគូ ថ្វាយដោយអត្ថថាមិនកន្ទក់ (នូវគ្នានឹងគ្នា) សីលវិសុទ្ធិ ថ្វាយដោយអត្ថថាសង្រួម ចិត្តវិសុទ្ធិ ថ្វាយដោយអត្ថថាមិនពយមាយ ទិដ្ឋិវិសុទ្ធិ ថ្វាយដោយអត្ថថាឃើញ វិមោក្ខ ថ្វាយដោយអត្ថថារួច វិជ្ជា ថ្វាយដោយអត្ថថាត្រាស់ដឹង វិមុត្តិ ថ្វាយដោយអត្ថថាលះចេញស្រឡះ ខយញ្ញាណ ថ្វាយដោយអត្ថថាផ្តាច់បង់ស្រឡះ អនុប្បាទញ្ញាណ ថ្វាយដោយអត្ថថារម្ងាប់ឆន្ទៈ ថ្វាយដោយអត្ថថាឫសគល់ មនសិការៈ ថ្វាយដោយអត្ថថាតាំងឡើងព្រម ផស្សៈ ថ្វាយដោយអត្ថថាប្រមូល វេទនា ថ្វាយដោយអត្ថថាប្រដុំចុះ សមាធិ ថ្វាយដោយអត្ថថាជាប្រធាន សតិ ថ្វាយដោយអត្ថថាជាអធិបតី បញ្ញា ថ្វាយដោយអត្ថថាត្រៃលែងជាងធម៌តាំងនោះ វិមុត្តិ ថ្វាយដោយអត្ថថាជារួម និព្វានឈ្មោះអមតៈ ជាទីពឹង (របស់សត្វ) ថ្វាយដោយអត្ថថាចប់ស្រេច (នៃកិច្ចក្នុងសាសនា) ។

ចប់ មណ្ឌបេយ្យកថា ។

ចប់ ភាណវារៈ ។

ចប់ មហាវគ្គ ទី ๑ ។

តស្ស វគ្គស្ស ទុតិយំ ភាណវារំ

ញាណនិដ្ឋេ ច អស្សាសា ឥន្ទ្រិយំ វិមោក្ខមញ្ញមា
កតិកម្មវិបល្លាសា មគ្គោ មណ្ឌនតេ ទសាតិ ។

ឯស និកាយវរេ បឋមោ អស្សាសោ បឋមោ ច
បវរេ វរមគ្គោតិ ។

ខុទ្ទានវគ្គោះគឺ

កថាវគ្គនោះមាន ញាណ ១ ទិដ្ឋិ ១ ការដកដង្កើមចេញ ១ ឥទ្ធិ ១ វិមោក្ខ ជាគំរប់ប្រាំ ១ គតិ ១ កម្ម ១ វិបល្លាស ១ មគ្គ ១ ដប់នឹងសភាពថ្លា ។

និកាយដ៏ប្រសើរនេះ លោកតំកល់ទុកហើយ មិនមានធម៌ដទៃស្មើផង ជាដំបូងផង សំខាន់ផង ជាមគ្គដ៏ប្រសើរផង ។

(៥) ឯវម្បេ សុតំ ឯកំ សមយំ អាយស្មា អានន្ទោ កោសម្ពិយំ វិហរតិ ឃោសិតារាមេ ។ តត្រ ខោ អាយស្មា អានន្ទោ ភិក្ខូ អាមន្តេសិ អាវុសោតិ ។ អាវុសោតិ ខោ តេ ភិក្ខូ អាយស្មតោ អានន្ទស្ស បច្ចស្សោសុំ ។ អាយស្មា អានន្ទោ ឯតទវោច យោ ហិ កោចិ អាវុសោ ភិក្ខុ វា ភិក្ខុនី វា មម សន្តិកេ អរហត្តំ ព្យាករោតិ សព្ពោ ចតូហិ មគ្គេហិ ឯតេសំ វា អញ្ញតរេន ភគវតោ ចតូហិ ។

តជាវុសោ ភិក្ខុ សមថបុព្ពង្គមំ វិបស្សនំ ភាវេតិ តស្ស សមថបុព្ពង្គមំ វិបស្សនំ ភាវយតោ មគ្គោ សញ្ជាយតិ សោ តំ មគ្គំ អាសេវតិ ភាវេតិ ពហុលីករោតិ តស្ស តំ មគ្គំ អាសេវតោ ភាវយតោ ពហុលីករោតោ សញ្ញោជនានិ បហីយន្តិ អនុសយា ព្យន្តីហោន្តិ ។

(៩) ខ្ញុំបានស្តាប់មកយ៉ាងនេះ សម័យមួយ ព្រះអានន្ទមានអាយុ គង់នៅក្នុងវត្តជេតវនារាម ទៀបក្រុងសាវត្ថី ។ ក្នុងទីនោះឯង ព្រះអានន្ទមានអាយុ បានហៅពួកភិក្ខុថា ម្នាលអាវុសោទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលស្តាប់ព្រះអានន្ទមានអាយុថា ករុណា អាវុសោ ។ ព្រះអានន្ទមានអាយុ បានពោលពាក្យនេះថា ម្នាលអាវុសោទាំងឡាយ បព្វជិតណាមួយ ទោះតិក្ខុត្តី តិក្ខុទ្ធត្តី ញ្ញាតរអរហត្តផលសំណាក់ខ្ញុំ ដោយមគ្គ ៤ សព្វគ្រប់ ឬដោយមគ្គទាំងនុ៎ះ មគ្គណាមួយ តើមគ្គទាំង ៤ ដូចម្តេចខ្លះ ។

ម្នាលអាវុសោទាំងឡាយ តិក្ខុក្នុងសាសនានេះ បំពេញវិបស្សនាមានសមថៈជាប្រធាន កាលតិក្ខុនោះ បំពេញវិបស្សនាមានសមថៈជាប្រធាន មគ្គរមែងកើតឡើង តិក្ខុនោះ ឈ្មោះថាសេព បំពេញ ធ្វើឲ្យច្រើន នូវមគ្គនោះ កាលតិក្ខុនោះ សេព បំពេញ ធ្វើឲ្យច្រើន នូវមគ្គនោះ តិក្ខុនោះកំលះបង់សញ្ញោជនៈទាំងឡាយ អនុសយទាំងឡាយក៏វិនាស ។

បុន ចបរំ អាវុសោ ភិក្ខុ វិបស្សនាបុព្ពង្គមំ សមថំ ភាវេតិ តស្ស វិបស្សនាបុព្ពង្គមំ សមថំ ភាវយតោ មគ្គោ សញ្ជាយតិ ។ សោ តំ មគ្គំ អាសេវតិ ភាវេតិ ពហុលីករោតិ តស្ស តំ មគ្គំ អាសេវតោ ភាវយតោ ពហុលីករោតោ សញ្ញោជនានិ បហីយន្តិ អនុសយា ព្យន្តីហោន្តិ ។

បុន ចបរំ អាវុសោ ភិក្ខុ សមថវិបស្សនំ យុគនទ្ធំ(១) ភាវេតិ តស្ស តំ សមថវិបស្សនំ យុគនទ្ធំ ភាវយតោ មគ្គោ សញ្ជាយតិ សោ តំ មគ្គំ អាសេវតិ ភាវេតិ ពហុលីករោតិ តស្ស តំ មគ្គំ អាសេវតោ ភាវយតោ ពហុលីករោតោ សញ្ញោជនានិ បហីយន្តិ អនុសយា ព្យន្តីហោន្តិ ។

បុន ចបរំ អាវុសោ ភិក្ខុនោ ធម្មុទ្ធច្ចវិក្ខេបាតមានសំ(២) ហោតិ សោ អាវុសោ សមយោ យន្តំ ចិត្តំ អជ្ឈត្តញ្ញេវ សន្តិដ្ឋតិ សន្និសីទតិ ឯកោទិ ហោតិ សមាធិយតិ តស្ស មគ្គោ សញ្ជាយតិ

---

១ ខ. ម. យុគនទ្ធំ ។ ២ ខ. ម. ធម្មុទ្ធច្ចវិក្ខេបាតមានសំ ។

ម្នាលអាវុសោ ចំណែកឯ មួយទៀត កិកូចំរើនសមថៈ មាន វិបស្សនាជាប្រធាន កាលកិកូនោះ ចំរើនសមថៈមានវិបស្សនាជាប្រធាន មគ្គក៏កើតឡើង កិកូនោះ ឈ្មោះថាសេព ចំរើន ធ្វើឲ្យច្រើន នូវមគ្គ នោះ កាលកិកូនោះ សេព ចំរើន ធ្វើឲ្យច្រើន នូវមគ្គនោះ កិកូនោះ ក៏លះសញ្ញោជនៈចាំង ឡាយ អនុសយចាំងឡាយក៏វិនាស ។

ម្នាលអាវុសោ ចំណែកឯ មួយទៀត កិកូចំរើនធម៌ ដែលជាប់គា ជាគូគឺសមថៈនឹងវិបស្សនា កាលកិកូនោះចំរើនធម៌ ដែលជាប់គាជាគូ គឺសមថៈ នឹងវិបស្សនានោះ មគ្គក៏កើតឡើង កិកូនោះ ឈ្មោះថាសេព ចំរើន ធ្វើឲ្យច្រើន នូវមគ្គនោះ កាលកិកូនោះសេព ចំរើន ធ្វើឲ្យច្រើន នូវមគ្គនោះ កិកូនោះក៏លះសញ្ញោជនៈចាំងឡាយ អនុសយចាំង ឡាយក៏វិនាស ។

ម្នាលអាវុសោ ចំណែកឯ មួយវិញទៀត កិកូមានចិត្តមិនច្រួលច្រាល ដោយទុច្ចរិតធម៌ ម្នាលអាវុសោ ចាំងឡាយ មានសម័យ ដែលចិត្តបិត ល្អ តាំងនៅស៊ប់ ជាចិត្តឯកឯក តាំងនៅមាំ មគ្គរបស់កិកូនោះ ក៏កើតឡើង

เสา ตำ มกฺกฏ อาเสวติ ภาเวติ พหุลีกโรติ ตสฺส ตำ มกฺกฏ อาเสวเต ภาวยเต พหุลีกโรเต สญฺโญชนานิ ปหียนฺติ อนุสยา ฆฏฺฏียนฺติ ฯ เยน หิ เกจิ อาวุเสา กิกฺกา กิกฺกนิ ก มม สนฺติเก อรหตฺตำ ปาปุณาติ สพฺเพสา ๙เมหิ จตูหิ มคฺเคหิ ฆเตสำ ก อญฺญตรเตติ ฯ

(๖) กตำ สมถปุพฺพงฺคมำ วิปสฺสนำ ภาเวติ ฯ เอกฺกมฺหาเสน จิตฺตสฺส ฯกคฺคตา อารมฺภเต สมาธิ สตฺต ชาเต ธมฺเม อนิจฺเจโต อนุปสฺสนเฏฺฐน วิปสฺสนา ทุกฺเขโต อนุปสฺสนเฏฺฐน วิปสฺสนา อนตฺเตโต อนุปสฺสนเฏฺฐน วิปสฺสนา ฯ ๙ติ ปมมำ ฯมเต ปญฺญา วิปสฺสนา เตน วุจฺจติ สมถปุพฺพงฺคมำ วิปสฺสนำ ภาเวติ(๑) ฯ

ภาเวตีติ จตสฺสา ภาวนา สตฺต ชาตานิ ฉนฺทนิ อนติวตฺตนเฏฺฐน ภาวนา ๙นฺทฺริยานิ ฯกาธิปเตยฺยเฏฺฐน ภาวนา สนุปตฺติยา ปหานเฏฺฐน ภาวนา อาเสวนเฏฺฐน ภาวนา ฯ

๑ ม. ภาเวตีติ ฯ

កិក្ខុនោះ ឈ្មោះថាសេខ ចំរើន ធ្វើឲ្យច្រើន នូវមគ្គនោះ កាលកិក្ខុនោះ សេខ ចំរើន ធ្វើឲ្យច្រើន នូវមគ្គនោះ កិក្ខុនោះកំលុះសញ្ញោជនៈ ទាំង៣ឲ្យ អនុស័យទាំង៣ឲ្យកំនាស ។ ម្នាលអាវុសោទាំង៣ឲ្យ បព្វជិតណាមួយ ទោះកិក្ខុក្តី កិក្ខុនីក្តី តែងព្យាករអរហត្តកង់សំណាក់ខ្ញុំ ដោយមគ្គទាំង ៤ នេះ សព្វគ្រប់ ឬដោយមគ្គៈទាំង៣នុ៎ះ មគ្គណាមួយ ។

(៦) កិក្ខុចំរើនវិបស្សនា មានសមថៈជាប្រធាន តើដូចម្តេច ។ ភាពនៃចិត្តមានអារម្មណ៍តែមួយ មិនពយមាយ ដោយអំណាចនៃនេក្ខម្មៈ ឈ្មោះថាសមាធិ ឈ្មោះថាវិបស្សនា ដោយអត្ថថាឃើញរឿយៗថាមិនទៀង ឈ្មោះថាវិបស្សនា ដោយអត្ថថាឃើញរឿយៗ ថាជាទុក្ខ ឈ្មោះថាវិបស្សនា ដោយអត្ថថាឃើញរឿយៗ ថាមិនមែនខ្លួន នូវធម៌ទាំង៣ឲ្យ ដែលកើតកង់សមាធិនោះ ។ សមថៈ (កើត) មុន វិបស្សនា (កើត) ក្រោយ ហេតុនោះ លោកពោលថា កិក្ខុចំរើនវិបស្សនា មានសមថៈជាប្រធាន ដោយប្រការដូច្នេះ ។

ពាក្យថា ចំរើន បានដល់ ការចំរើន(ភាវនា) ៤ យ៉ាង គឺ ការចំរើនដោយអត្ថថាមិនកន្ធង នូវធម៌ទាំង៣ឲ្យ ដែលកើតកង់សមាធិនោះ ១ ការចំរើន ដោយអត្ថថាមានរសតែមួយ នៃឥន្ទ្រិយទាំង៣ឲ្យ ១ ការចំរើន ដោយអត្ថថានាំទៅដោយវិរិយៈ ដ៏សមគួរដល់ឥន្ទ្រិយនោះ ១ ការចំរើន ដោយអត្ថថាទស្សហ៍សេខ ១ ។

មត្តំ សញ្ញាយតីតំ កេចិ មត្តំ សញ្ញាយតំ ឧស្សទដ្ឋេន សម្មាទិដ្ឋិ មត្តំ សញ្ញាយតំ អភិរោបនដ្ឋេន សម្មាសង្កប្បោ មត្តំ សញ្ញាយតំ បរិក្ខហនដ្ឋេន សម្មាវាចា មត្តំ សញ្ញាយតំ សមុដ្ឋានដ្ឋេន សម្មាកម្មន្តោ មត្តំ សញ្ញាយតំ វោទានដ្ឋេន សម្មាអាជីវោ មត្តំ សញ្ញាយតំ បគ្គហដ្ឋេន សម្មាវាយាមោ មត្តំ សញ្ញាយតំ ឧបដ្ឋានដ្ឋេន សម្មាសតិ មត្តំ សញ្ញាយតំ អវិក្ខេបដ្ឋេន សម្មាសមាធិ មត្តំ សញ្ញាយតំ ឯវំ មត្តំ សញ្ញាយតំ ។

សោ តំ មត្តំ អាសេវតិ ភាវេតិ ពហុលីករោតីតំ អាសេវតីតំ កេចិ អាសេវតំ ។ អាវជ្ជោ អាសេវតំ ជានោ អាសេវតំ បស្សោ អាសេវតំ បច្ចវេក្ខោ អាសេវតំ ចិត្តំ អធិដ្ឋហោ អាសេវតំ សទ្ធាយ អធិមុច្ចោ អាសេវតំ វីរិយំ បគ្គណ្ហោ អាសេវតំ សតិំ ឧបដ្ឋាបេសោ អាសេវតំ ចិត្តំ សមាធហោ អាសេវតំ បញ្ញាយ បជានោ

សំនួរត្រង់ពាក្យថា មគ្គក៏កើតឡើង តើមគ្គកើតឡើង ដូចម្តេច មគ្គគឺសម្មាទិដ្ឋិ ដោយអត្ថថាឃើញ កើតឡើង មគ្គគឺសម្មាសង្កប្បៈ ដោយអត្ថថា លើកចិត្តឡើង (កាន់អារម្មណ៍) កើតឡើង មគ្គគឺសម្មាវាចា ដោយអត្ថថាកំណត់ កើតឡើង មគ្គគឺសម្មាកម្មន្តៈ ដោយអត្ថថាខះខៀង កើតឡើង មគ្គគឺសម្មាអាជីវៈ ដោយអត្ថថាផ្សះផង់ កើតឡើង មគ្គគឺសម្មាវាយាមៈ ដោយអត្ថថាផ្គងទុក កើតឡើង មគ្គគឺសម្មាសតិ ដោយអត្ថថាប្រុង កើតឡើង មគ្គគឺសម្មាសមាធិ ដោយអត្ថថាមិនពយមាយ កើតឡើង មគ្គកើតឡើង យ៉ាងនេះឯង ។

អធិប្បាយពាក្យថា តត្ថនោះ ឈ្មោះថាសេត បំរើន ធ្វើឲ្យច្រើន នូវមគ្គនោះ ត្រង់ពាក្យថា សេត តើសេតដូចម្តេច ។ តត្ថកាលនឹកំពុងតែ (នូវមគ្គ) ឈ្មោះថាសេត កាលដឹង ឈ្មោះថាសេត កាលឃើញ ឈ្មោះថាសេត កាលពិចារណា ឈ្មោះថាសេត កាលអធិដ្ឋានទូវចិត្ត ឈ្មោះថាសេត កាលដឿសិប់ដោយសទ្ធា ឈ្មោះថាសេត កាលផ្គងនូវព្យាយាម ឈ្មោះថាសេត កាលប្រុងនូវស្មារតី ឈ្មោះថាសេត កាលតំកល់ទុកនូវចិត្ត ឈ្មោះថាសេត កាលដឹងច្បាស់ដោយបញ្ញា ឈ្មោះថាសេត

អាសេវតំ អភិញ្ញេយ្យំ អភិជានន្តោ អាសេវតំ បរិ-
ញ្ញេយ្យំ បរិជានន្តោ អាសេវតំ បហាតព្ពំ បជហន្តោ
អាសេវតំ ភាវេតព្ពំ ភាវេន្តោ អាសេវតំ សច្ឆិកាតព្ពំ
សច្ឆិករោន្តោ អាសេវតំ ឃវំ អាសេវតំ ។

ភាវេតីតំ កថំ ភាវេតិ ។ អាវជ្ជន្តោ ភាវេតិ
ជានន្តោ ភាវេតិ បស្សន្តោ ភាវេតិ បច្ចវេក្ខន្តោ
ភាវេតិ ចិត្តំ អធិដ្ឋហន្តោ ភាវេតិ សទ្ធាយ អធិមុច្ច-
ន្តោ ភាវេតិ វីរិយំ បគ្គណ្ហន្តោ ភាវេតិ សតិំ ឧបដ្ឋា-
បេន្តោ ភាវេតិ ចិត្តំ សមាធហន្តោ ភាវេតិ បញ្ញាយ
បជានន្តោ ភាវេតិ អភិញ្ញេយ្យំ អភិជានន្តោ ភាវេតិ
បរិញ្ញេយ្យំ បរិជានន្តោ ភាវេតិ បហាតព្ពំ បជហន្តោ
ភាវេតិ ភាវេតព្ពំ ភាវេន្តោ ភាវេតិ សច្ឆិកាតព្ពំ
សច្ឆិករោន្តោ ភាវេតិ ឃវំ ភាវេតិ ។

កាលដឹងចំពោះនូវធម៌ដែលគួរដឹង ឈ្មោះថាសេព កាលកំណត់ដឹងនូវធម៌ដែលគួរកំណត់ដឹង ឈ្មោះថាសេព កាលលះនូវធម៌ដែលគួរលះ ឈ្មោះថាសេព កាលចំរើននូវធម៌ដែលគួរចំរើន ឈ្មោះថាសេព កិក្ខុ កាលធ្វើឲ្យជាក់ច្បាស់ នូវធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ ឈ្មោះថាសេព កិក្ខុសេព យ៉ាងនេះឯង ។

សំនួរត្រង់ពាក្យថា ចំរើន តើចំរើនដូចម្តេច ។ កិក្ខុកាលនឹកំពឹងរក ឈ្មោះថាចំរើន កាលដឹង ឈ្មោះថាចំរើន កាលឃើញ ឈ្មោះថាចំរើន កាលពិចារណា ឈ្មោះថាចំរើន កាលអធិដ្ឋាននូវចិត្ត ឈ្មោះថាចំរើន កាលផ្ទឿសិប់ដោយសទ្ធា ឈ្មោះថាចំរើន កាលផ្គងព្យាយាម ឈ្មោះថាចំរើន កាលប្រុងស្មារតី ឈ្មោះថាចំរើន កាលតំកល់ខ្ពុតនូវចិត្ត ឈ្មោះថាចំរើន កាលដឹងច្បាស់ដោយបញ្ញា ឈ្មោះថាចំរើន កាលដឹងចំពោះនូវធម៌ដែលគួរដឹង ឈ្មោះថាចំរើន កាលកំណត់ដឹងនូវធម៌ដែលគួរកំណត់ដឹង ឈ្មោះថាចំរើន កាលលះនូវធម៌ដែលគួរលះ ឈ្មោះថាចំរើន កាលចំរើននូវធម៌ដែលគួរចំរើន ឈ្មោះថាចំរើន កាលធ្វើឲ្យជាក់ច្បាស់នូវធម៌ ដែលគួរធ្វើឲ្យជាក់ច្បាស់ ឈ្មោះថាចំរើន កិក្ខុចំរើន យ៉ាងនេះឯង ។

ពហុលីកភោតីតិ កថំ ពហុលីកភោតិ ។ អាវជ្ជន្តោ ពហុលីកភោតិ ជានន្តោ ពហុលីកភោតិ បស្សន្តោ ពហុលីកភោតិ បច្ចវេក្ខន្តោ ពហុលីកភោតិ ចិត្តំ អធិដ្ឋហន្តោ ពហុលីកភោតិ សទ្ធាយ អធិមុច្ចន្តោ ពហុលីកភោតិ វីរិយំ បគ្គណ្ហន្តោ ពហុលីកភោតិ សតិំ ឧបដ្ឋាបេន្តោ ពហុលីកភោតិ ចិត្តំ សមាធហន្តោ ពហុលីកភោតិ បញ្ញាយ បជានន្តោ ពហុលីកភោតិ អភិញ្ញេយ្យំ អភិជានន្តោ ពហុលីកភោតិ បរិញ្ញេយ្យំ បរិជានន្តោ ពហុលីកភោតិ បហាតព្ពំ បជហន្តោ ពហុលីកភោតិ ភាវេតព្ពំ ភាវេន្តោ ពហុលីកភោតិ សច្ឆិកាតព្ពំ សច្ឆិកភោន្តោ ពហុលីកភោតិ ឯវំ ពហុលីកភោតិ ។

តស្ស តំ មក្កំ អាសេវតោ ភាវយតោ ពហុលីកភោតោ សញ្ញោជនានិ បហីយន្តិ អនុសយា ព្យន្តីហោន្តីតិ កថំ សញ្ញោជនានិ បហីយន្តិ អនុសយា ព្យន្តីហោន្តិ ។

សំនួរត្រង់ពាក្យថា ធ្វើឲ្យច្រើន តើធ្វើឲ្យច្រើនដូចម្តេច ? កិកុ
កាលទឹករំពឹងរក ឈ្មោះថាធ្វើឲ្យច្រើន កាលដឹង ឈ្មោះថាធ្វើឲ្យច្រើន
កាលឃើញ ឈ្មោះថាធ្វើឲ្យច្រើន កាលពិចារណា ឈ្មោះថាធ្វើឲ្យច្រើន
កាលអធិដ្ឋានន្ទូវចិត្ត ឈ្មោះថាធ្វើឲ្យច្រើន កាលដឿសិប់ដោយសទ្ធា
ឈ្មោះថាធ្វើឲ្យច្រើន កាលផ្គងព្យាយាម ឈ្មោះថាធ្វើឲ្យច្រើន កាលប្រុង
ស្មារតី ឈ្មោះថាធ្វើឲ្យច្រើន កាលតំកល់ទុកន្ទូវចិត្ត ឈ្មោះថាធ្វើឲ្យ
ច្រើន កាលដឹងច្បាស់ដោយបញ្ញា ឈ្មោះថាធ្វើឲ្យច្រើន កាលដឹងចំពោះ
ន្ទូវធម៌ដែលគួរដឹង ឈ្មោះថាធ្វើឲ្យច្រើន កាលកំណត់ដឹងន្ទូវធម៌ដែល
គួរកំណត់ដឹង ឈ្មោះថាធ្វើឲ្យច្រើន កាលលះន្ទូវធម៌ដែលគួរលះ ឈ្មោះ
ថាធ្វើឲ្យច្រើន កាលចំរើនន្ទូវធម៌ដែលគួរចំរើន ឈ្មោះថាធ្វើឲ្យច្រើន
កាលធ្វើជាក់ច្បាស់ន្ទូវធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ ឈ្មោះថាធ្វើឲ្យច្រើន
កិកុធ្វើឲ្យច្រើន យ៉ាងនេះឯង ។

សំនួរត្រង់ពាក្យថា កាលកិកុនោះ សេព ចំរើន ធ្វើឲ្យច្រើន នូវមគ្គ
នោះ កិកុនោះកំលះសញ្ញោជន:ទាំងឡាយ អនុស័យទាំងឡាយកំនើនាស
តើកិកុលះសញ្ញោជន:ទាំងឡាយ អនុស័យទាំងឡាយកំនើនាស ដូចម្តេច ។

សោតាបត្តិមគ្គេន សក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្ពតមហាសោ ឥមានិ តីណិ សញ្ញោជនានិ បហីយន្តិ ឥដ្ឋានុសយោ វិចិកិច្ឆានុសយោ ឥមេ ទ្វេ អនុសយា ព្យន្តីហោន្តិ ។

សកទាគាមិមគ្គេន ទិដ្ឋិវិសំ តាមកតសញ្ញោជនំ បដិឃសញ្ញោជនំ ឥមានិ ទ្វេ សញ្ញោជនានិ បហីយន្តិ ទិដ្ឋិវិតោ តាមកតានុសយោ បដិឃានុសយោ ឥមេ ទ្វេ អនុសយា ព្យន្តីហោន្តិ ។

អនាគាមិមគ្គេន អណុសហគតំ តាមកតសញ្ញោជនំ បដិឃសញ្ញោជនំ ឥមានិ ទ្វេ សញ្ញោជនានិ បហីយន្តិ អណុសហគតោ តាមកតានុសយោ បដិឃានុសយោ ឥមេ ទ្វេ អនុសយា ព្យន្តីហោន្តិ ។

អរហត្តមគ្គេន រូបរាគោ អរូបរាគោ មានោ ឧទ្ធច្ចំ អវិជ្ជា ឥមានិ បញ្ច សញ្ញោជនានិ បហីយន្តិ មានានុសយោ ភវរាគានុសយោ អវិជ្ជានុសយោ ឥមេ តយោ អនុសយា ព្យន្តីហោន្តិ ឯវំ សញ្ញោជនានិ បហីយន្តិ អនុសយា ព្យន្តីហោន្តិ ។

កិក្ខុលះសញ្ញោជន: ៣ នេះ គឺសក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វត-
បរាមាស អនុស័យ ២ នេះ គឺទិដ្ឋានុស័យ វិចិកិច្ឆានុស័យ កំនាស
ដោយសោតាបត្តិមគ្គ ។

លះសញ្ញោជន: ២ នេះ គឺកាមរាគសញ្ញោជន: បដិឃសញ្ញោជន:
ជំគ្រោតគ្រោត អនុស័យ ២ នេះ គឺកាមរាគានុស័យ បដិឃានុស័យ:
ជំគ្រោតគ្រោត កំនាស ដោយសកទាគាមិមគ្គ ។

លះសញ្ញោជន: ២ នេះ គឺកាមរាគសញ្ញោជន: បដិឃសញ្ញោជន:
ជំល្អិត អនុស័យ ២ នេះ គឺកាមរាគានុស័យ បដិឃានុស័យ ជំល្អិត
កំនាស ដោយអនាគាមិមគ្គ ។

លះសញ្ញោជន:៥នេះ គឺរូបរាគ: អរូបរាគ: មាន: ឧទ្ធច្ច: អវិជ្ជា
អនុស័យ ៣ នេះ គឺមានានុស័យ ភវរាគានុស័យ អវិជ្ជានុស័យ: កំនាស
ដោយអរហត្តមគ្គ កិក្ខុលះសញ្ញោជន:ទាំង៦យ អនុស័យទាំង៦យ
កំនាស យ៉ាងនេះឯង ។

(๗) អព្យាបាទវសេន ចិត្តស្ស ឯកគ្គតា អវិក្ខេបោ សមាធិ អាលោកសញ្ញាវសេន ចិត្តស្ស ឯកគ្គតា អវិក្ខេបោ សមាធិ ។បេ។ បដិនិស្សគ្គានុបស្សី អស្សាសវសេន... បដិនិស្សគ្គានុបស្សី បស្សាសវសេន ចិត្តស្ស ឯកគ្គតា អវិក្ខេបោ សមាធិ តត្ថ ជាតេ ធម្មេ អនិច្ចតោ អនុបស្សនដ្ឋេន វិបស្សនា ទុក្ខតោ អនុបស្សនដ្ឋេន វិបស្សនា អនត្តតោ អនុបស្សនដ្ឋេន វិបស្សនា ។ ឥតិ បឋមំ សមថោ បច្ឆា វិបស្សនា តេន វុច្ចតិ សមថបុព្ពង្គមំ វិបស្សនំ ភាវេតិ ។

ភាវេតីតិ ឧតុសេ្បា ភាវនា តត្ថ ជាតានំ ធម្មានំ អនតិវត្តនដ្ឋេន ភាវនា ឥន្ទ្រិយានំ ឯករសដ្ឋេន ភាវនា តទុបគវីរិយវាហនដ្ឋេន ភាវនា អាសេវនដ្ឋេន ភាវនា ។

(៧) ភាពនៃចិត្តមានអារម្មណ៍តែមួយ មិនពយមាយ ដោយអំណាច ឥតព្យាបាទ ឈ្មោះថាសមាធិ ភាពនៃចិត្តមានអារម្មណ៍តែមួយ មិនពយមាយ ដោយអំណាចនៃការសំគាល់ពន្លឺ ឈ្មោះថាសមាធិ ។បេ។ ភាពនៃចិត្តមានអារម្មណ៍តែមួយ មិនពយមាយ ដោយអំណាចនៃដង្ហើមចេញរបស់បុគ្គលអ្នកឃើញរឿយ ។ក្នុងការរលាស់ខ្លួនចេញ... ដោយអំណាចនៃដង្ហើមចូល របស់បុគ្គលអ្នកឃើញរឿយ ។ ក្នុងការរលាស់ខ្លួនចេញ ឈ្មោះថាសមាធិ ឈ្មោះថាវិបស្សនា ដោយអត្ថថាឃើញរឿយ ។ ថាមិនទៀង ឈ្មោះថាវិបស្សនា ដោយអត្ថថាឃើញរឿយៗថាជាទុក្ខ ឈ្មោះថាវិបស្សនា ដោយអត្ថថាឃើញរឿយៗ ថាមិនមែនខ្លួន នូវធម៌ទាំងឡាយដែលកើតក្នុងសមាធិនោះ សមថៈ (កើត) មុន វិបស្សនា (កើត) ក្រោយ ហេតុនោះ លោកពោលថា ភិក្ខុចំរើនវិបស្សនាមានសមថៈជាប្រធានដោយប្រការដូច្នេះ ។

ពាក្យថា ចំរើន បានដល់ការចំរើន(ភាវនា) ៤ យ៉ាង គឺការចំរើនដោយអត្ថថាមិនកន្ធត់នូវធម៌ទាំងឡាយ ដែលកើតក្នុងសមាធិនោះ ១ ការចំរើន ដោយអត្ថថាមានរសតែមួយនៃឥន្ទ្រិយទាំងឡាយ ១ ការចំរើនដោយអត្ថថានាំទៅដោយវីរិយៈដ៏សមគួរដល់ឥន្ទ្រិយនោះ ១ ការចំរើនដោយអត្ថថាឧស្សាហ៍សេព ១ ។

វត្តោ សញ្ជាយតីតំ កេ៎ មត្តោ សញ្ជាយតំ ។ ឧសរ្ជនដ្ឋេន សម្ភាធិដ្ឋំ មត្តោ សញ្ជាយតំ អភិ-ភេរនដ្ឋេន សម្ភាសន្តិប្បត្តោ មត្តោ សញ្ជាយតំ ។បេ។ អវិក្ខេបដ្ឋេន សម្ភាសមាធិ មត្តោ សញ្ជាយតំ ឯវំ មត្តោ សញ្ជាយតំ ។

សោ តំ មក្ខំ អាសេវតំ ភាវេតំ ពហុលីកភេតីតំ អាសេវតីតំ កេ៎ អាសេវតំ ។ អាវជ្ជន្តោ អាសេវតំ ជានន្តោ អាសេវតំ ។បេ។ សច្ចិកាតុំ សច្ចិកភេ-ន្តោ អាសេវតំ ឯវំ អាសេវតំ ។

ភាវេតីតំ កេ៎ ភាវេតំ ។ អាវជ្ជន្តោ ភាវេតំ ជានន្តោ ភាវេតំ ។បេ។ សច្ចិកាតុំ សច្ចិកភេន្តោ ភាវេតំ ឯវំ ភាវេតំ ។

ពហុលីភេតីតំ កេ៎ ពហុលីកភេតំ ។ អាវជ្ជន្តោ ពហុលីកភេតំ ជានន្តោ ពហុលីកភេតំ ។បេ។ សច្ចិកាតុំ សច្ចិកភេន្តោ ពហុលីកភេតំ ឯវំ ពហុលីកភេតំ ។

សំនួរត្រង់ពាក្យថា មគ្គក៏កើតឡើង តើមគ្គកើតឡើង ដូចម្តេច ។ មគ្គគឺសម្មាទិដ្ឋិ ដោយអត្ថថាឃើញ កើតឡើង មគ្គគឺសម្មាសង្កប្បៈ ដោយអត្ថថាលើកចិត្តឡើង (កាន់អារម្មណ៍) កើតឡើង ។ បេ ។ មគ្គគឺសម្មាសមាធិ ដោយអត្ថថាមិនពយមាយ កើតឡើង មគ្គកើតឡើង យ៉ាងនេះឯង ។

អធិប្បាយពាក្យថា កិកុនោះឈ្មោះថាសេព បំរើន ធ្វើឲ្យច្រើននូវមគ្គនោះ ត្រង់ពាក្យថា សេព តើសេពដូចម្តេច ។ កិកុកាលនឹកំរំពឹងរក ឈ្មោះថាសេព កាលដឹង ឈ្មោះថាសេព ។ បេ ។ កាលធ្វើឲ្យជាក់ច្បាស់ នូវធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ ឈ្មោះថាសេព កិកុសេព យ៉ាងនេះឯង ។

សំនួរត្រង់ពាក្យថា បំរើន តើបំរើន ដូចម្តេច ។ កិកុកាលនឹកំរំពឹងរក (នូវមគ្គ) ឈ្មោះថាបំរើន កាលដឹង ឈ្មោះថាបំរើន ។ បេ ។ កាលធ្វើឲ្យជាក់ច្បាស់ នូវធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ ឈ្មោះថាបំរើន កិកុបំរើន យ៉ាងនេះឯង ។

សំនួរត្រង់ពាក្យថា ធ្វើឲ្យច្រើន តើធ្វើឲ្យច្រើនដូចម្តេច ។ កិកុកាលនឹកំរំពឹង (នូវមគ្គ) ឈ្មោះថាធ្វើឲ្យច្រើន កាលដឹង ឈ្មោះថាធ្វើឲ្យច្រើន ។ បេ ។ កាលធ្វើឲ្យជាក់ច្បាស់ នូវធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ ឈ្មោះថាធ្វើឲ្យច្រើន កិកុធ្វើឲ្យច្រើន យ៉ាងនេះឯង ។

តស្ស តំ មក្កំ អាសេវតោ ភាវយតោ ពហុ-លីករោតោ សញ្ញោជនានិ បហីយន្តិ អនុសយា ព្យន្តីហោន្តីតិ កថំ សញ្ញោជនានិ បហីយន្តិ អនុ-សយា ព្យន្តីហោន្តិ ។

សោតាបត្តិមគ្គេន សក្កាយទិដ្ឋិ វិចិកិច្ឆា សី-លព្ពតបរាមាសោ ឥមានិ តីណិ សញ្ញោជនានិ បហីយន្តិ អដ្ឋានុសយោ វិចិកិច្ឆានុសយោ ឥមេ ទ្វេ អនុសយា ព្យន្តីហោន្តិ ។

សកទាគាមិមគ្គេន ឱឡារិកំ កាមរាគសញ្ញោ-ជនំ បដិឃសញ្ញោជនំ ឥមានិ ទ្វេ សញ្ញោជនានិ បហីយន្តិ ឱឡារិកោ កាមរាគានុសយោ បដិឃានុ-សយោ ឥមេ ទ្វេ អនុសយា ព្យន្តីហោន្តិ ។

អនាគាមិមគ្គេន អណុសហគតំ កាមរាគសញ្ញោ-ជនំ បដិឃសញ្ញោជនំ ឥមានិ ទ្វេ សញ្ញោជនានិ បហីយន្តិ អណុសហគតោ កាមរាគានុសយោ ប-ដិឃានុសយោ ឥមេ ទ្វេ អនុសយា ព្យន្តីហោន្តិ ។

សំនួរត្រង់ពាក្យថា កាលកិលេសនោះ សោត ចំរើន ធ្វើឲ្យច្រើន នូវមគ្គនោះ កិលេសនោះ ក៏លះសញ្ញោជន:ទាំងឡាយ អនុស័យទាំងឡាយ ក៏វិនាស តើកិលេសសញ្ញោជន:ទាំងឡាយ អនុស័យទាំងឡាយក៏វិនាស ដូចម្តេចខ្លះ ។

(៧) កិលេសសញ្ញោជន: ៣ នេះ គឺ សក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាស ដោយសោតាបត្តិមគ្គ អនុស័យ ២ នេះ គឺ ទិដ្ឋានុស័យ វិចិកិច្ឆានុស័យ ក៏វិនាស ។

កិលេសសញ្ញោជន: ២ នេះ គឺកាមរាគសញ្ញោជន: បដិឃសញ្ញោជន: ដ៏គ្រោតគ្រាត ដោយសកទាគាមិមគ្គ អនុស័យ ២ នេះ គឺ កាមរាគានុស័យ បដិឃានុស័យ ដ៏គ្រោតគ្រាត ក៏វិនាស ។

កិលេសសញ្ញោជន: ២ នេះ គឺ កាមរាគសញ្ញោជន: បដិឃសញ្ញោជន: ដ៏ល្អិត ដោយអនាគាមិមគ្គ អនុស័យ ២ នេះ គឺ កាមរាគានុស័យ បដិឃានុស័យ: ដ៏ល្អិត ក៏វិនាស ។

អរហត្តមគ្គេន វូបភវតោ អរូបភវតោ មានោ ខន្ធេសុ អវិជ្ជា ឥមានិ បញ្ច សញ្ញោជនានិ បហីយន្តិ មានានុសយោ ភវរាគានុសយោ អវិជ្ជានុសយោ ឥមេ តយោ អនុសយា ព្យន្តីហោន្តិ ឯវំ សញ្ញោជនានិ បហីយន្តិ អនុសយា ព្យន្តីហោន្តិ ឯវំ សមថបុព្ពង្គមំ វិបស្សនំ ភាវេតិ ។

(ជ) កថំ វិបស្សនាបុព្ពង្គមំ សមថំ ភាវេតិ ។ អនិច្ចតោ អនុបស្សនដ្ឋេន វិបស្សនា ទុក្ខតោ អនុបស្សនដ្ឋេន វិបស្សនា អនត្តតោ អនុបស្សនដ្ឋេន វិបស្សនា តត្ថ ជាតានំ ធម្មានំ ច ហេស្សត្តាវម្មណតា ចិត្តស្ស ឯកគ្គតា អវិក្ខេបោ សមាធិ ឥតិ បឋមំ វិបស្សនា បច្ឆា សមថោ តេន វុច្ចតិ វិបស្សនាបុព្ពង្គមំ សមថំ ភាវេតិ ។

ភាវេតីតិ ឧតសេវ្ហ ភាវនា ។បេ។ អាសេវនដ្ឋេន ភាវនា ។បេ។ មគ្គោ សញ្ញាយតីតិ កថំ មគ្គោ សញ្ញាយតិ ។បេ។ ឯវំ មគ្គោ សញ្ញាយតិ ។បេ។

កិក្ខុ លះសញ្ញោជន: ៩ នេះ គឺ រូបភគ: អរូបភគ: មាន: ទុក្ខ: អវិជ្ជា ដោយអរហត្តមគ្គ អនុស័យ ៣ នេះ គឺ មានានុស័យ ភវរាគានុស័យ អវិជ្ជានុស័យ ក៏វិនាស កិក្ខុ លះសញ្ញោជន: ទាំងឆ្ងាយ អនុស័យទាំងឆ្ងាយ ក៏វិនាស យ៉ាងនេះ កិក្ខុចំរើនវិបស្សនា មានសមថ: ជាប្រធាន យ៉ាងនេះឯង ។

(៨) កិក្ខុចំរើនសមថ: មានវិបស្សនាជាប្រធាន តើដូចម្តេច ។ វិបស្សនា ដោយអត្ថថាឃើញរឿយ ។ ថាមិនទៀង វិបស្សនា ដោយអត្ថថាឃើញរឿយ ។ ថាជាទុក្ខ វិបស្សនា ដោយអត្ថថាឃើញរឿយ ។ ថាមិនមែនខ្លួន មួយទៀត ភាពនៃធម៌ទាំងឆ្ងាយ ដែលកើតកង់សមាធិ នោះ មានអារម្មណ៍តួរលះ ភាពនៃចិត្តមានអារម្មណ៍តែមួយ ការមិនកយមាយ ឈ្មោះថាសមាធិ វិបស្សនា (កើត) មុន សមថ: (កើត) ក្រោយ ហេតុនោះ លោកពោលថា កិក្ខុចំរើនសមថ: មានវិបស្សនា ជាប្រធាន ដោយប្រការដូច្នេះ ។

ពាក្យថា ចំរើន ចានដល់ការចំរើន ៤ យ៉ាង ។បេ។ ការចំរើន ដោយអត្ថថាទស្សនៈសេព ។បេ។ សំនួរត្រង់ពាក្យថា មគ្គកើតឡើង តើមគ្គកើតឡើង ដូចម្តេច ។បេ។ មគ្គកើតឡើង យ៉ាងនេះ ។បេ។

ฯลฯ สญฺโญชนานิ ปหียนฺติ อนุสยา ปฏินิสฺสชฺชนฺติ ฯ
รูปํ อนิจฺจโต อนุปสฺสนาเญน วิปสฺสนา รูปํ ทุกฺขโต อนุปสฺสนาเญน วิปสฺสนา รูปํ อนตฺตโต อนุปสฺสนาเญน วิปสฺสนา ตสฺส ฌานสฺส ฌานารมฺมณานิ จ เวทนาย ฌานารมฺมณานิ จ สญฺญาย ฌานารมฺมณานิ จ สงฺขารานํ ฌานารมฺมณานิ จ วิญฺญาณสฺส ฌานารมฺมณานิ อนิจฺจโต อนุปสฺสนาเญน วิปสฺสนา ฌานารมฺมณานิ ทุกฺขโต ฯเปฯ อนตฺตโต อนุปสฺสนาเญน วิปสฺสนา ตสฺส ฌานสฺส ฌานารมฺมณานิ จ เวทนาย ฌานารมฺมณานิ จ สญฺญาย ฌานารมฺมณานิ จ สงฺขารานํ ฌานารมฺมณานิ จ วิญฺญาณสฺส ฌานารมฺมณานิ นิพฺพิทานุปสฺสนาเญน วิปสฺสนา ฌานารมฺมณานิ วิราคานุปสฺสนาเญน วิปสฺสนา ฌานารมฺมณานิ นิโรธานุปสฺสนาเญน วิปสฺสนา ฌานารมฺมณานิ ปฏินิสฺสคฺคานุปสฺสนาเญน วิปสฺสนา ฌานารมฺมณานิ ขยานุปสฺสนาเญน วิปสฺสนา ฌานารมฺมณานิ วยานุปสฺสนาเญน วิปสฺสนา ฌานารมฺมณานิ วิปริณามานุปสฺสนาเญน วิปสฺสนา ฌานารมฺมณานิ อนิมิตฺตานุปสฺสนาเญน วิปสฺสนา ฌานารมฺมณานิ อปฺปณิหิตานุปสฺสนาเญน วิปสฺสนา ฌานารมฺมณานิ สุญฺญตานุปสฺสนาเญน วิปสฺสนา ฌานารมฺมณานิ อธิปญฺญาธมฺมวิปสฺสนาเญน วิปสฺสนา ฌานารมฺมณานิ ยถาภูตญาเญน วิปสฺสนา ฌานารมฺมณานิ อาทีนวานุปสฺสนาเญน วิปสฺสนา ฌานารมฺมณานิ ปฏิสงฺขานุปสฺสนาเญน วิปสฺสนา ฌานารมฺมณานิ วิวฏฺฏนานุปสฺสนาเญน วิปสฺสนา ฌานารมฺมณานิ โสตาปตฺติมคฺคกฺขณโต ปฏฺฐาย ยาว อรหตฺตมคฺคกฺขณา ตตฺถ ปญฺญินฺทฺริยาธิปเตยฺยา ตสฺส ฌานสฺส ฌานสมฺปยุตฺตา ธมฺมา ฌานารมฺมณานิ จ ฯเปฯ

កិត្តនោះក៏លះសញ្ញោជន: ចាំង ឆ្ងាយ អនុស័យចាំង ឆ្ងាយក៏វិនាស យ៉ាង នេះ ។ វិបស្សនា ដោយអត្ថថាឃើញរឿយៗ នូវរូប ថាមិនទៀង វិបស្សនា ដោយអត្ថថាឃើញរឿយៗ នូវរូប ថាជាទុក្ខ វិបស្សនា ដោយអត្ថថាឃើញរឿយៗ នូវរូប ថាមិនមែនខ្លួន មួយទៀត ភាពនៃធម៌ចាំង ឆ្ងាយ ដែលកើតកង់សមាធិនោះ មានអារម្មណ៍តួរលះ ភាពនៃចិត្តមានអារម្មណ៍តែមួយ ការមិនរាយមាយ ឈ្មោះថាសមាធិ វិបស្សនា (កើត) មុន សមថ: (កើត) ក្រោយ ហេតុនោះ លោកពោលថា កិត្តិចំរើនសមថ: មានវិបស្សនាជាប្រធាន ដោយប្រការដូច្នេះ ។

ពាក្យថា ចំរើន បានដល់ការចំរើន ៤ យ៉ាង ។បេ។ ការចំរើនដោយអត្ថថាទស្សាហ៍សេព ។បេ។ សំនួរត្រង់ពាក្យថា មគ្គ កើតឡើង ។បេ។ មគ្គកើតឡើងយ៉ាងនេះ ។បេ។ កិត្តនោះក៏លះសញ្ញោជន: ចាំង ឆ្ងាយ អនុស័យចាំង ឆ្ងាយ ក៏វិនាស ។ វិបស្សនា ដោយអត្ថថាឃើញរឿយៗ នូវវេទនា សញ្ញា សង្ខារ វិញ្ញាណ ចក្ខុ ។បេ។ នូវជរាមរណ: ថាមិនទៀង វិបស្សនា ដោយអត្ថថាឃើញរឿយៗ នូវជរាមរណ: ថាជាទុក្ខ ។បេ។ ថាមិនមែនខ្លួន មួយទៀត ភាពនៃធម៌ចាំង ឆ្ងាយ ដែលកើតកង់សមាធិនោះ មានអារម្មណ៍តួរលះ ភាពនៃចិត្តមានអារម្មណ៍តែមួយ

អរិដ្ឋោ សមាធិ ឥតិ បឋមំ វិបស្សនា បជ្ជា សមថោ តេន វុច្ចតិ វិបស្សនាបុព្វង្គមំ សមថំ ភាវេតិ ។ ភាវេតីតិ ចតស្សោ ភាវនា ។ បេ ។ សញ្ញាយតីតិ កថំ មគ្គោ សញ្ញាយតិ ។ បេ ។ ឯវំ មគ្គោ សញ្ញាយតិ ។ បេ ។ ឯវំ សញ្ញោជនានំ បហានំ អនុសយា ព្យន្តីហោន្តិ ឯវំ វិបស្សនាបុព្វង្គមំ សមថំ ភាវេតិ ។

(๙) កថំ សមថវិបស្សនំ យុគនទ្ធំ ភាវេតិ ។ សោឡសហិ អាការេហិ សមថវិបស្សនំ យុគនទ្ធំ ភាវេតិ អារម្មណាជ្ជន គោចរាជ្ជន បហានាជ្ជន បរិញ្ញាកាជ្ជន វដ្ដានាជ្ជន វិវដ្ដនាជ្ជន សន្តាជ្ជន បណីតាជ្ជន វិមុត្តាជ្ជន អធិដ្ឋានាជ្ជន តទារម្មណាជ្ជន អនិមិត្តាជ្ជន អប្បណិហិតាជ្ជន សុញ្ញាជ្ជន វិភាវនាជ្ជន អនិមិត្តាជ្ជន យុគនទ្ធាជ្ជន ។

ការមិនពយមាយ ឈ្មោះថាសមាធិ វិបស្សនា (កើត) មុន សមថៈ (កើត) ក្រោយ ហេតុនោះ លោកពោលថា កិក្ខុចំរើនសមថៈ មានវិបស្សនាជាប្រធាន ដោយប្រការដូច្នេះ ។

ពាក្យថា ចំរើន បានដល់ការចំរើន ៤ យ៉ាង ។បេ។ សំនួរត្រង់ពាក្យថា មគ្គកើតឡើង តើមគ្គកើតឡើងដូចម្តេច ។បេ។ មគ្គកើតឡើងយ៉ាងនេះ ។បេ។ កិក្ខុនោះក៏លះសញ្ញោជនៈតាំងពីរឡាយ អនុស័យតាំងពីរឡាយ ក៏វិនាសយ៉ាងនេះ កិក្ខុចំរើនសមថៈមានវិបស្សនាជាប្រធាន យ៉ាងនេះឯង ។

(៨) កិក្ខុចំរើនធម៌ដែលជាប់គាំជាគូ គឺសមថៈនឹងវិបស្សនា តើដូចម្តេច ។ កិក្ខុចំរើនធម៌ដែលជាប់គាំជាគូ គឺសមថៈនឹងវិបស្សនា ដោយអាការ ១៦ គឺដោយអត្ថថាជាអារម្មណ៍ ១ ដោយអត្ថថាជាគោចរ ១ ដោយអត្ថថាលះបង់ ១ ដោយអត្ថថាលះស្រឡះ ១ ដោយអត្ថថាបេញ្ច ១ ដោយអត្ថថាប្រែត្រឡប់ ១ ដោយអត្ថថាស្ងប់ ១ ដោយអត្ថថាឧត្តម ១ ដោយអត្ថថារួចស្រឡះ ១ ដោយអត្ថថាមិនមានអាសវៈ ១ ដោយអត្ថថាធ្លុង ១ ដោយអត្ថថាមិនមាននិមិត្ត ១ ដោយអត្ថថាមិនមានទីតំកល់ ១ ដោយអត្ថថាសូន្យ ១ ដោយអត្ថថាមានរសតែមួយ ១ ដោយអត្ថថាមិនកន្ទួងជាប់គាំជាគូនឹងគ្នា ១ ។

កថំ អារម្មណាដ្ឋេន សមថវិបស្សនំ យុគនទ្ធំ ភាវេតិ ។ ខុទ្ទកំ បដិបទាតោ ចិត្តស្ស វិក្ខេបតា អវិក្ខេបោ សមាធិ និមិត្តារម្មណោ អវិជ្ជំ បដិបទាតោ អនុបស្សនដ្ឋេន វិបស្សនា និមិត្តារម្មណា ឥតិ អារម្មណាដ្ឋេន សមថវិបស្សនា វិការសោ បោនទ្ធំ យុគនទ្ធា បោនទ្ធំ អញ្ញមញ្ញំ នាតិវត្តន្តីតិ តេន វុច្ចតិ អារម្មណាដ្ឋេន សមថវិបស្សនំ យុគនទ្ធំ ភាវេតិ ។

ភាវេតីតិ ចតស្សោ ភាវនា ។ បេ ។ អាសេវនដ្ឋេន ភាវនា ។ បេ ។ មគ្គោ សញ្ញាយតីតិ កថំ មគ្គោ សញ្ញាយតិ ។ បេ ។ ឯវំ មគ្គោ សញ្ញាយតិ ឯវំ សញ្ញោជនានិ បហីយន្តិ អនុសយា ព្យន្តីហោន្តិ ឯវំ អារម្មណាដ្ឋេន សមថវិបស្សនំ យុគនទ្ធំ ភាវេតិ ។

កថំ គោចរដ្ឋេន សមថវិបស្សនំ យុគនទ្ធំ ភាវេតិ ។ ខុទ្ទកំ បដិបទាតោ ចិត្តស្ស វិក្ខេបតា អវិក្ខេបោ សមាធិ គោចរគោចរោ អវិជ្ជំ បដិបទាតោ អនុបស្សនដ្ឋេន វិបស្សនា គោចរគោចរា ឥតិ គោចរដ្ឋេន

កិក្ខុំ បំរើនធម្មិ ដែលជាប់គាំជាគូ គឺសមថៈនឹងវិបស្សនា ដោយអត្ថថាជាអារម្មណ៍ តើដូចម្តេច ។ កាលបុគ្គលលះទុច្ចរិតៈ ភាពនៃចិត្តមានអារម្មណ៍តែមួយ ការមិនពយមាយ គឺសមាធិ មាននិកេធជាអារម្មណ៍ កាលបុគ្គលលះអវិជ្ជា វិបស្សនា ដោយអត្ថថាឃើញរឿយ ។ ក៏មាននិកេធជាអារម្មណ៍ដែរ សមថៈនឹងវិបស្សនា ដោយអត្ថថាជាអារម្មណ៍ ជាគុណជាតិមានរសតែមួយ ជាប់គាំជាគូ មិនកន្ធឹងទូគាំនឹងគ្នា ដោយប្រការដូច្នេះ ព្រោះហេតុនោះ លោកទើបពោលថា កិក្ខុំបំរើនធម្មិដែលជាប់គាំជាគូ គឺសមថៈនឹងវិបស្សនា ដោយអត្ថថាជាអារម្មណ៍ ។

ពាក្យថា បំរើន បានដល់ការបំរើន ៤ យ៉ាង ។បេ។ ការបំរើន ដោយអត្ថថា ទស្សាហ៍សេព ។បេ។ សំនួរត្រង់ពាក្យថា មគ្គកើតឡើង តើមគ្គកើតឡើង ដូចម្តេច ។បេ។ មគ្គកើតឡើង យ៉ាងនេះ កិក្ខុនោះលះសញ្ញោជនៈទាំងឡាយ អនុស័យទាំងឡាយក៏នាសៈ យ៉ាងនេះ កិក្ខុំបំរើនធម្មិ ដែលជាប់គាំជាគូ គឺសមថៈនឹងវិបស្សនា ដោយអត្ថថាជាអារម្មណ៍យ៉ាងនេះឯង ។

កិក្ខុំបំរើនធម្មិដែលជាប់គាំជាគូ គឺសមថៈនឹងវិបស្សនា ដោយអត្ថថាជាគោចរ តើដូចម្តេច ។ កាលបុគ្គលលះទុច្ចរិតៈ ភាពនៃចិត្តមានអារម្មណ៍តែមួយ ការមិនពយមាយ គឺសមាធិ មាននិកេធជាគោចរ កាលបុគ្គលលះអវិជ្ជា វិបស្សនា ដោយអត្ថថាឃើញរឿយ ។ ក៏មាននិកេធជាគោចរដែរ

សមថវិបស្សនា ឯការម្មា ហោន្តុ យុគនទ្ធា ហោន្តុ អញ្ញមញ្ញំ នាតិវត្តន្តីតិ តេន វុច្ចតិ គោចរដ្ឋេន សមថ-វិបស្សនំ យុគនទ្ធំ ភាវេតិ ។

(๑๐) កថំ បហានដ្ឋេន សមថវិបស្សនំ យុគន-ទ្ធំ ភាវេតិ ។ ទុទ្ទិដ្ឋសហគតក្កិលេសេ ច ខន្ធេ ច បជហតោ ចិត្តស្ស ឯកគ្គតា អវិក្ខេបោ សមាធិ និព្ពេធគោចរោ អវិជ្ជាសហគតក្កិលេសេ ច ខន្ធេ ច បជហតោ អនុបស្សនដ្ឋេន វិបស្សនា និព្ពេធគោចរា ឥតិ បហានដ្ឋេន សមថវិបស្សនា ឯការម្មា ហោន្តុ យុគនទ្ធា ហោន្តុ អញ្ញមញ្ញំ នាតិវត្តន្តីតិ តេន វុច្ចតិ បហានដ្ឋេន សមថវិបស្សនំ យុគនទ្ធំ ភាវេតិ ។

កថំ បរិញ្ញាដ្ឋេន សមថវិបស្សនំ យុគនទ្ធំ ភា-វេតិ ។ ទុទ្ទិដ្ឋសហគតក្កិលេសេ ច ខន្ធេ ច បរិញ្ញតោ ចិត្តស្ស ឯកគ្គតា អវិក្ខេបោ សមាធិ និព្ពេធគោចរោ អវិជ្ជាសហគតក្កិលេសេ ច កន្ធេ ច បរិញ្ញតោ អនុ-បស្សនដ្ឋេន វិបស្សនា និព្ពេធគោចរា ឥតិ បរិញ្ញាដ្ឋេន

សមថៈនឹងវិបស្សនា ដោយអត្ថថាជាគោចរ ជាគុណជាតិមានរសតែមួយ ជាប់គ្នាជាគូ មិនកន្ធឹងនូវគ្នានឹងគ្នា ដោយប្រការដូច្នេះ ព្រោះហេតុនោះ លោកទើបពោលថា កិក្ខុចំរើនធម៌ ដែលជាប់គ្នាជាគូ គឺសមថៈនឹងវិបស្សនា ដោយអត្ថថាជាគោចរ ។

